1: 8 et 9. (Mitsalapali) reçu le 28-2-52

# មិត្តសាលាបាលី

INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

ទស្សនាវដ្ដីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ

ចេញរាល់ខែ



Août - Septembre

ឆ្នាំទី ២ សីហា - កញ្ញា លេខ ៨-៩

ព.ស. ២៤៩៤ — គ.ស. ១៩៥១

ទស្សនាវដ្ដីអនុមាសផ្សាយព្រះពុទ្ធសាសនានិងអក្សរសាស្ត្រខ្មែរ

បណ្ណាធិការ ឈឹម-ក្រសេម

សំណាក់ការ លេខ ៣៥ អា., វីថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ

## បញ្ជីរឿង

| | | ទំព័រ |
|---|---|---|
| វិបារណកថា | | ២៨១ |
| បុណ្យគឺអ្វី? | ភិក្ខុប៉ាង-ខាត់ | ២៨៥ |
| សង្គហធម៌ (តនឹងចប់) | ព្រះបាឡាត់ពោធិភាម ជា-ទន់ | ៣០៨ |
| ព្រះរាជប្រវត្តិព្រះបាទសម្ដេចព្រះស្រីធម្មរាជា | | ៣២៦ |
| ការកសាងខ្លួនដើម្បីទទួលសេចក្ដីសុខ (តមក) | ហេង-យ៉ាន់ | ៣៣៥ |
| សកុន្តលា (តមក) | ហេង-យ៉ាន់ | ៣៤៦ |
| បញ្ចតន្ត្រៈ (តមក) | សេចក្ដីប្រែរបស់ភិក្ខុប៉ាង-ខាត់ | ៣៥៤ |

ដំឡៃជាវប្រចាំឆ្នាំ ១០០ រៀល

អ្នកអានទាំងឡាយ! សូមអញ្ជើញចុះឈ្មោះជាវ!
នឹងបបួលញាតិមិត្តជួយជាវ!
ជីវិតទស្សនាវដ្ដីសូមផ្ញើលើលោកអ្នក ។

លេខចុះ :
លេខបញ្ជី :

# វិចារណកថា

ព្រះពុទ្ធសាសនាបានលើកយកចិត្តទុកជាប្រធានលើធម៌ទាំងឡាយ ៗ ធម៌ទាំងឡាយនោះ មានចិត្តដល់មុន មានចិត្តប្រសើរដោយវិសេស សម្រេចហើយដោយចិត្ត ៗ គំនិត ក៏ថា ឬអំពើដែលប្រកបដោយចិត្តប្រទុស្ត តែងនាំសេចក្តីទុក្ខមកឲ្យ, បើប្រកបដោយចិត្តជ្រះថ្លាវិញ តែងនាំសុខមកឲ្យ បីដូចស្រមោលដែលអន្ទោលតាមប្រាណ ៗ ឯចិត្តនេះ តាមបកតិភាពជាសភាវបរិសុទ្ធស្អាត ជាបភស្សរចិត្ត, តែដែលនឹងប្រែទៅជាសៅហ្មងបាន ព្រោះមានឧបក្កិលេសចូលមកលាយឡំធ្វើឲ្យកករល្អក់ ៗ

ការដែលយើងដឹងបានព្រោះអាស្រ័យលោកខាងក្រៅ អាចប្រមូលរួបរួមជាចិន្តាឬជាធម៌ ៗ ចិន្តាឬធម៌ទាំងឡាយនោះនឹងជាខ្មៅឬជាសជាល្អឬជាអាក្រក់ ជាគុណឬជាទោស ស្រេចហើយតែក្នុងវេលានោះៗ ចិត្តជាកុសលឬជាអកុសល គឺថាបើប្រកបដោយមូលហេតុ ៣ យ៉ាងគឺ លោភៈ ទោសៈ មោហៈ ចិត្តជាអកុសលនាំនូវសេចក្តីវិនាសមកឲ្យ បើប្រាសចាកអកុសលមូលទាំង ៣ ប្រការនោះ ចិត្តជាកុសលនាំនូវសេចក្តីចំរើនមកឲ្យ ព្រោះហេតុនោះ ទើបលោកពោលថា ការហ្វឹកហ្វឺនចិត្តបានល្អជាហេតុនាំឲ្យបានជួបប្រទះនូវសេចក្តីសុខ សេចក្តីចំរើន ៗ ដូច្នេះ យើងជាអ្នកកាន់ព្រះពុទ្ធសាសនា ត្រូវមានកិច្ចសំខាន់ក្នុងការជុះខាត់ចិត្ត

ឲ្យស្អាតបាតអកុសល គឺលោភៈ ទោសៈ មោហៈ ។ តែយើងនឹងកំចាត់នូវសត្រូវទាំង ៣ ប្រភេទនេះបាន លុះត្រាតែយើងបានស្គាល់នូវសត្រូវទាំងនោះដោយច្បាស់លាស់ ។

លោភៈ គឺសេចក្ដីននះននាតចង់បាន មានកិរិយាជាប់ជំពាក់ក្នុងអារម្មណ៍ជាលក្ខណៈ បីដូចពានរដែលជាប់ជ័រឈើ ។ លោភៈនេះមានកិច្ចធ្វើចិត្តឲ្យអែបស្និទ្ធក្នុងវដ្ឋិយារម្មណ៍ ពោលគឺវត្ថុកាម ឲ្យក្ដៅក្រហាយពេលភល បីដូចសាច់ដែលបុគ្គលបោះទៅលើថ្មក្ដៅ មានកិរិយាមិនបានបរិច្ចាគជាផល មានតែការហួងហែងថែរក្សាទាំងកណ្ដាលយប់ទាំងកណ្ដាលថ្ងៃតតស្រាកស្រាន្ត សំដែងនូវអាការស្រេកឃ្លានមិនឈប់ឈរ ជាហេតុនាំសត្វទៅកាន់បដិវិស័យ ។ សេចក្ដីលោភគ្របសង្កត់មិនឲ្យយល់សេចក្ដីប្រែប្រួលនៃសង្ខារទឹងវ័យរបស់ខ្លួន ជាហេតុបាំងអនិច្ចំ ឲ្យជាប់ជំពាក់តែក្នុងការបរិភោគកាម ប្រព្រឹត្តកាមសុខល្លិកានុយោគ ។

ទោសៈ គឺសេចក្ដីប្រទុសរាយមិនពេញចិត្ត ក្នុងសត្វនិងសង្ខារ មានកិរិយាកាចជាលក្ខណៈ បីដូចពស់កំណាចចាំដកពពារសំដែងអាការប្រឹងទឹងប៉ឹក មានកិរិយាដុតបំផ្លាញនូវទីដែលខ្លួននៅជានិច្ច ប្រៀបដូចភ្លើងឆេះព្រៃ មានសភាវៈប្រទុសរាយបំផ្លាញខ្លួនឯងនិងអ្នកដទៃ ជាផលអាក្រក់សាមាន្យបីដូចជាថ្នាំពុលមានការបង់ពៀរវេរាគំនុំគុំគួនជានិច្ច ជា

ហេតុនាំសត្វទៅកាន់នរក ។ ទោសៈជាគ្រឿងបិទបាំងគំនិតឲ្យឃើញ ជាខ្លួនគ្រាន់បើ ខ្លួនត្រូវតែម្យ៉ាង ឥតបេះកោតញញើតអ្នកឯណាឡើយ មិនឲ្យឃើញទុក្ខខ្លួននឹងទុក្ខអ្នកដទៃ ច្រើនតែនាំឲ្យប្រព្រឹត្តតឹងរ៉ឹងហួសហេតុ រកផលប្រយោជន៍គ្មាន គឺឲ្យចូលចិត្តប្រកបអត្តកិលមថានុយោគ ។

មោហៈ គឺសេចក្តីវង្វេងក្នុងអារម្មណ៍ មានសភាវៈងងឹតងងល់នៃចិត្តជាលក្ខណៈ មានសភាវៈមិនដឹងការត្រូវ ដឹងតែខុសជាកិច្ច មិនបានប្រតិបត្តិត្រូវជាផល ជាហេតុនាំសត្វឲ្យទៅកើតជាតិរច្ឆាន បាំងមិនឲ្យចាក់ធ្លុះនូវសាមញ្ញលក្ខណៈដ៏សំខាន់នៃអារម្មណ៍ គឺអនត្តា រៀបជាសំគាល់ថានុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ រកឱកាសនឹងដកខ្លួនត្រូវពុំបាន វង្វេងប្រព្រឹត្តតែមិច្ឆាបដិបទា ផ្លូវនៃសេចក្តីវិនាស ។

អកុសលមូលទាំង៣ យើងបានស្គាល់លក្ខណៈ កិច្ចនឹងផលដោយច្បាស់ហើយ ឃើញពិតជាសត្រូវគួរចៀសវាងគួរកំចាត់ចេញឆ្ងាយ សត្រូវទី ១ រាំងរាផ្លូវចងយើងឲ្យជាប់នៅតែមួយកន្លែងធ្វើសេចក្តីចំរើនពុំកើត ; សត្រូវទី ២ ដុតពេលពលយើង ឲ្យបញ្ចេញអាការៈដូចយក្ស បំផ្លាញទាំងប្រយោជន៍អ្នកដទៃទាំងប្រយោជន៍ខ្លួនឯង ; សត្រូវទី ៣ ជាសេចក្តីងងឹតបាំងបិទជុំជិតមិនឲ្យរកផ្លូវឃើញ ។ ក្រៃលែងជាងនេះទៅទៀត សត្រូវទាំង ៣ ជាមេហាមឃាត់មិនឲ្យចាប់កំណើតជាមនុស្ស ។ ឯការកើតជាមនុស្សនេះជាការក្រៃក្រពេក ផងផ្លូវដែលជាប់ក្នុងក្របកមានចំនួន

តិចពន់ពេក បើនឹងយកទៅប្រៀបជាមួយនឹងផង់ធូលីដែលមាននៅក្នុង
លោកយ៉ាងណាមិញ ឯសត្វដែលបានកើតជាមនុស្សមានចំនួនតិចជាង
សត្វដែលវិលវល់ក្នុងទីដទៃជាច្រើនភាគ ក៏យ៉ាងនោះដែរ ។

មានតែការចាប់ជាតិជាមនុស្សប៉ុណ្ណោះទេ ទើបសត្វអាចមានឱកាស
នឹងកែខ្លួនឲ្យរួចរំដោះផុតចាកទុក្ខទាំងពួងបាន ។ ការដែលយើងរាល់គ្នា
បានកើតជាមនុស្សហើយ ទុកជាកំពូលមួយដ៏ប្រសើរក្រៃលែង មិនគួរឲ្យ
កំពូលនោះកន្លងយើងបាត់ទៅក្នុងជាតិមុខៗទៀតឡើយ គឺថាត្រូវតែយើងខំ
ប្រឹងប្រែងខ្នះខ្នែងដោយពេញកម្លាំង ដើម្បីស្ងួនរក្សានូវមនុស្សវិស័យនោះ
ដោយការអប់រំមនុស្សធម៌ឲ្យតាំងខ្ជាប់ក្នុងខ្លួនជានិច្ចកាល មនុស្សធម៌នេះ
ស្ថិតក្នុងការបង្ក្រាបនូវលោភៈ ទោសៈ មោហៈ ដែលពន្លិចយើងទៅ
កាន់ទីទាប ។ ដូច្នេះយើងគប្បីពិចារណាខ្លួនយើង ដោយខ្លួនយើង
គ្រប់ៗពេល ឲ្យបានដឹងដោយច្បាស់លាស់ថា តើគំនិតដែលយើងគិត
វាចាដែលយើងនិយាយ អំពើដែលយើងធ្វើ មានប្រឡូកប្រឡាក់ដោយ
មន្ទិលគឺ អកុសលមូលទាំង ៣ នេះឬទេ បើមាន តោងហាមឃាត់ចិត្ត
កុំឲ្យគិត មាត់កុំឲ្យនិយាយ ជើងដៃកុំឲ្យធ្វើ ។

ការប្រតិបត្តិបែបនោះជាការកសាងខ្លួនយើងឲ្យបានជាគតិដ៏ប្រសើរ
ដល់ខ្លួនយើង ជាកល្យាណមិត្តដ៏ប្រពៃដែលអាចដឹកនាំយើងទៅកាន់
ឧត្តមគតិដ៏ខ្ពង់ខ្ពស់ ។

ម្នាលអានន្ទ! អ្នកណាមួយ ទោះជាភិក្ខុក្តី ជាភិក្ខុនីក្តី ជាឧបាសកក្តី ជាឧបាសិកាក្តី ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌, អ្នកនោះទើបឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អាន នឹងបូជា ចំពោះតថាគត ដោយការបូជាដ៏ប្រសើរបំផុត ។

មហាបរិនិព្វានសូត្រ មហា. ទីឃ.

# បុណ្យ គឺអ្វី?

ពាក្យថា វិញ្ញនធម៌ អរិយធម៌ តែងផុះចេញពីមាត់នៃជនអ្នកប្រាជ្ញា សេចក្តីល្អទូទៅ, ម្តេចក៏បេះនិយាយ? ចុះបុណ្យដូចម្តេចក៏គេមិនត្រូវនិយាយ? បុណ្យមិនមែនជាសេចក្តីល្អឬអ្វី? បានជាបបួលគ្នានិយាយលាន់ថា មិនដឹងជាឯងធ្វើបុណ្យអ្វី? សំដីនេះដូចជាពាក្យនៃជនជំពូកខ្វះ ដែលនិយាយឌឺដងថា "មិនដឹងជាឯងគិតគូរពីទឹកដីអ្វី? គិតពីឯកពាក្យអ្វី?" ដែរ ៗ តាមពិត, ពាក្យពីរបីម៉ាត់នេះ មិនសមបើហាមាត់និយាយកើតសោះ គួរឆ្ងល់ណាស់!!! ។ បើតាមមតិអ្នកប្រាជ្ញលោកមិនឆ្ងល់ទេ លោកឲ្យឈ្មោះរួចស្រេចហើយ ៗ ពាក្យអកុសលបែបនេះ តែងកើតមានឡើងហើយលេចឮខ្ទរទូទៅ ជាពាក្យអកុសលនៃជនដែលមានបាតដៃប្រទាក់ដោយមច្ឆរិយធម៌មិនដែលធ្វើបុណ្យសោះ នៃជន

អសប្បុរសមិនមានសទ្ធា នៃជនល្ងង់ខ្លៅចិត្តអាក្រក់ អប្បឥតប្រាជ្ញាមើលឃើញខ្លី មិនស្គាល់ប្រយោជន៍ធំទូលាយ បើនិយាយខ្លីគឺជាពាក្យនៃជនខ្លាចបុណ្យហើយហ៊ានធ្វើបាប ។ ការធ្វើនយោបាយគិតគូរពីទឹកដី ជាផ្លូវនាំឲ្យប្រទេសជាតិមានវឌ្ឍនធម៌មានអរិយធម៌លូតលាស់ដុះដាលចំរើនឡើងយ៉ាងណា, ឯការបំពេញកុសលធ្វើបុណ្យទាន ក៏ជាផ្លូវដឹកនាំឲ្យលោកសន្និវាសទាំងមូលបានសេចក្តីសុខ-ចំរើនយ៉ាងនោះដែរ ។ អ្នកធ្វើនយោបាយ ហ៊ានលះបង់ជីវិតកាយធ្វើជាដីជាពលីដើម្បីចំរើនប្រទេស-ជាតិយ៉ាងណា អ្នកប្រាថ្នាបុណ្យក៏ហ៊ានបរិច្ចាគទ្រព្យព្រមទាំងជីវិតជំមុះមុគ ដើម្បីចំរើនព្រះពុទ្ធសាសនាយ៉ាងនោះដែរ ។ ព្រះវេស្សន្តរលះបង់នាងមទ្រីក្រិស្នាជាលី ក៏ព្រោះតែក្តីចំរើនពុទ្ធសាសនា ។ មនុស្សខ្លាចបុណ្យមើលមិនឃើញប្រយោជន៍ធំទូលាយទេ បានជាកំណាញ់មិនហ៊ានធ្វើបុណ្យ ឃើញត្រឹមតែយកទ្រព្យខ្លួនដែលខំប្រឹងរកបានមកដោយលំបាកទៅឲ្យគេទទេឥតប្រយោជន៍ ហើយមិនឃើញបានអ្វីមកខ្លួនវិញសោះ ឬគិតឃើញត្រឹមតែជាអ្នកសាសនាបោកខ្លួនឲ្យធ្វើបុណ្យប៉ុណ្ណោះ ។ តាមទស្សនៈអ្នកប្រាជ្ញយល់ផ្សេងពីនេះ គឺលោកយល់ថា ផ្លូវលោកជាធម៌នាំឲ្យបានសេចក្តីចំរើនមួយចំណែក, ឯផ្លូវធម៌ក៏ជាផ្លូវមួយនាំឲ្យចំរើនមួយចំណែក ។ លោកនេះ មានគន្លងពីរ គឺផ្លូវលោក នឹងផ្លូវធម៌ផ្លូវទាំងពីរនេះ ត្រូវដើរទៅជាមួយគ្នា លះបង់គ្នាមិនបាន ដូចរទេះដើរ

តែកង់មួយមិនបានដូច្នោះ បើដើរតែផ្លូវលោកមួយចំណែក លោកនេះនឹងឆេះទៅជាភ្លើង បើដើរតែផ្លូវធម៌មួយចំណែក លោកនេះនឹងរលីបរលាបណាស់ ៗ ផ្លូវលោកផ្លូវធម៌នេះ មិនមានតុល្យភាពស្មើគ្នាទេ បើលើកយកមកដាក់លើជញ្ជីងត្រាជូហើយថ្លឹងមើលនឹងឃើញថាផ្លូវធម៌មានទម្ងន់ធ្ងន់ជាងផ្លូវលោក ព្រោះផ្លូវលោក បានគ្រាន់តែធ្វើឲ្យសំបូរហូរហៀរដោយគ្រឿងឧបករណ៍ កើតសេចក្ដីសុខ - ចំរើនចំពោះមុខជាលោកវិស័យ ហើយក៏រលត់រលាយសាបរលាបបាត់បង់ទៅវិញតាមកាលវេលាអស់រលីង ; ឯផ្លូវធម៌ធ្វើឲ្យកើតសេចក្ដីសុខ - ចំរើនទៅនាលោកនេះផង ហើយមិនបាត់បង់សាបសូន្យទៅតាមកាលវេលាផង មិនប៉ុន្ដែប៉ុណ្ណោះទេ អាចជូនដំណើរសព្វសត្វទៅកាន់បរលោក បំពេញសេចក្ដីចំរើនទៅអនាគតវែងឆ្ងាយ រហូតទៅដល់ទីបំផុតគឺសេចក្ដីសុខក្នុងព្រះនិព្វានដែលមនុស្សលោកខ្វាចទៅទៀតផង ៗ

បុរាណសុភាសិតលោកពោលទុកជាគ្រឿងដាស់តឿនសតិថា “សស្ត្រ-វិជ្ជានិងសាស្ត្រវិជ្ជាទាំងពីរនេះ គួរប្រតិបត្តិរៀនឲ្យចេះដឹងទាំងអស់ វិជ្ជាទីមួយខាងដើម (សស្ត្រវិជ្ជា) កើតចំរើនឡើង ដើម្បីសើចលេងជាតុកកំប្លែង, វិជ្ជាទីពីរខាងចុង (សាស្ត្រវិជ្ជា) បុគ្គលគួរគោរពក្នុងកាលទាំងពួង” ៗ មួយទៀត, ផ្លូវលោកជាសម្ភារៈ (matérialisme) ជាឧបករណ៍ខាងកសាងរូបកាយ គឺការកសាងប្រទេសជាតិឲ្យមានគ្រឿង

ឧបករណ៍គ្រឿងឧបភោគបរិភោគ គ្រឿងអលង្ការមាសពេជ្រពិទូរ្យសូរ្យ-
កាន្ត សំលៀកបំពាក់ឆើតឆាយ មានរបៀបរៀបរយ, មានគេហដ្ឋាន,
ប្រាង្គប្រាសាទពាជនិវេសន៍, គមនាគមន៍, ជលយាន, ថលយាន,
អាកាសយាន ។ល។ ធ្វើឲ្យសំបូរជាហេតុនាំឲ្យកើតសុខស្រួលនៅនា-
លោកនេះ តែមិនមែនជាឧបករណ៍ខាងផ្លូវចិត្តធ្វើចិត្តឲ្យស្ងប់ក្សេមក្សាន្តទេ
ព្រមទាំងមិនអាចជួយសត្វឲ្យរួចពីសង្សារធំ គឺសេចក្ដីទុក្ខដែលកើតពីជាតិ
ជរា ព្យាធិ មរណៈ បានឡើយ ។ ឯផ្លូវធម៌ ( Spéritualisme ) ជាគ្រឿង
ឧបករណ៍ផ្លូវចិត្ត គឺការកសាងចិត្តឲ្យបានប្រសើរខ្ពង់ខ្ពស់ ដឹកនាំលោក
សន្និវាសទាំងមូលឲ្យបានសេចក្ដីសុខ-ចំរើនក្នុងទីចំពោះមុខផង ទៅអនា-
គតវែងឆ្ងាយទៀតផង ព្រមទាំងឲ្យបានរួចពីសង្សារធំគឺសេចក្ដីទុក្ខ ដែល
កើតពីជាតិ ជរា ព្យាធិ មរណៈ ថែមទៀត ។ ការកសាងចិត្តជាការៈធ្ងន់
ណាស់ ។ រូបកាយមនុស្សយើងនេះជាគ្រោងឆ្អឹងទទេ បើចិត្តនៅខាង
ក្នុងឥតមានអាហារគឺចំណេះវិជ្ជាឥតមានការសិក្សាបរិបូណ៌ហើយ ទៅជា
ចិត្តមិនប្រសើរ មិនមានប្រយោជន៍ទេ ។ ការប្រសើរខ្ពង់ខ្ពស់នៃមនុស្ស
នៅត្រង់ចិត្តប្រសើរ បើចិត្តវិកលខូចហើយ សូម្បីរូបកាយល្អដូចទេវតា
ក៏ប្រើការមិនបានដូចគ្រោងឆ្អឹងនៅលើផែនដី ។ ព្រោះហេតុនេះឯង
ហើយ បានជាអ្នកប្រាជ្ញទាំងឡាយដែលលោកឃើញប្រយោជន៍ធំទូលាយ
តែងប្រាថ្នាសេចក្ដីចំរើនដល់លោក ទើបលោកសំដែងទុកជាឲ្យធ្វើបុណ្យ

សមដូចពុទ្ធភាសិតមួយថា : " ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំខ្លាចបុណ្យ ពាក្យថាបុណ្យនេះជាឈ្មោះនៃសេចក្តីសុខទេ " ។

សត្វលោកចង់បានសេចក្តីសុខ ហើយខ្លាចបុណ្យ ព្រោះមិនស្គាល់ហេតុដែលនាំឲ្យកើតសេចក្តីសុខ សំគាល់ទុក្ខថាជាសុខ សុខថាជាទុក្ខ សំគាល់ធម៌ជាអធម៌, សំគាល់អធម៌ជាធម៌វិញ ដូចបុរាណសុភាសិតថា " យល់លាមកថាជាផ្កា " ។ ចិត្តបែបនេះ លោកហៅថាវិបល្លាស: ។ វិបល្លាស:មាន ៣ ប្រការគឺ : សញ្ញាវិបល្លាស: ១ ចិត្តវិបល្លាស: ១ ទិដ្ឋិវិបល្លាស. ១ ។ កាលបើមានវិបល្លាស:ហើយ នាំឲ្យសំគាល់ផ្ទុយខុសពីសេចក្តីពិត យកអនិច្ចំ ទុក្ខំ អនត្តា អសុភំ ថាជា និច្ចំ សុខំ អត្តា សុភំ ទៅវិញគឺ :–

១ – សំគាល់អនិច្ចំថាជានិច្ចំ ដែលឃ្លាតចាកសេចក្តីពិត ជាសញ្ញាវិបល្លាស ;

២ – ចូលចិត្តអនិច្ចំថាជានិច្ចំ ដែលឃ្លាតចាកសេចក្តីពិត ជាចិត្តវិបល្លាស ;

៣ – យល់ឃើញអនិច្ចំថាជានិច្ចំ ដែលឃ្លាតចាកសេចក្តីពិត ជាទិដ្ឋិវិបល្លាស ;

៤ – សំគាល់ទុក្ខថាជាសុខ ដែលឃ្លាតចាកសេចក្តីពិត ជាសញ្ញាវិបល្លាស ;

៥ – ប៉ូលចិត្តទុក្ខថាជាសុខ ដែលឃ្លាតចាកសេចក្តីពិត ជាចិត្តវិបល្លាស ;

៦ – យល់ឃើញទុក្ខថាជាសុខ ដែលឃ្លាតចាកសេចក្តីពិត ជាទិដ្ឋិវិបល្លាស ;

៧ – សំគាល់អនត្តាថាជាអត្តា ដែលឃ្លាតចាកសេចក្តីពិត ជាសញ្ញាវិបល្លាស ;

៨ – ប៉ូលចិត្តអនត្តាថាជាអត្តា ដែលឃ្លាតចាកសេចក្តីពិត ជាចិត្តវិបល្លាស ;

៩ – យល់ឃើញអនត្តាថាជាអត្តា ដែលឃ្លាតចាកសេចក្តីពិត ជាទិដ្ឋិវិបល្លាស ;

១០ – សំគាល់អសុភថាជាសុភ ដែលឃ្លាតចាកសេចក្តីពិត ជាសញ្ញាវិបល្លាស ;

១១ – ប៉ូលចិត្តអសុភថាជាសុភ ដែលឃ្លាតចាកសេចក្តីពិត ជាចិត្តវិបល្លាស ;

១២ – យល់ឃើញអសុភថាជាសុភ ដែលឃ្លាតចាកសេចក្តីពិត ជាទិដ្ឋិវិបល្លាស ។

វិបល្លាសធម៌នេះហើយ ដែលជាធម៌អកុសលបិទផ្លូវមិនឲ្យយល់សេចក្តីពិត មិនឲ្យមើលឃើញបុណ្យ មើលឃើញបុណ្យថាជាបាប

ម្ល៉ោះហើយបានជាខ្លាចបុណ្យ មិនហ៊ានធ្វើបុណ្យ, ឲ្យមើលឃើញ បាបថាជាបុណ្យ ហើយហ៊ានធ្វើតែបាប លុះបាបឲ្យផលមក បានសុទ្ធតែវេទនា ។ សត្វលោកនេះ មើលឃើញលោកនេះដែលពេញដោយភ្លើងទុក្ខគឺ ជាតិ ជរា ព្យាធិ មរណៈ ថាជាសុខ ដូចមមាចឃើញភ្លើងយល់ថាត្រជាក់សប្បាយ ។ ក្នុងលោកនេះ សេចក្ដីសុខមានបន្តិចបន្តួចដែលកើតមកពីអាមិសៈគឺទ្រព្យសម្បត្តិ សេចក្ដីសុខជានិរាមិសៈមិនមានសោះទេ ។ សត្វលោកណាកើតមកនៅក្នុងលោកភ្លើងនេះ ហើយយល់ថាជាសុខស្រួល មិនរកឧបាយរើខ្លួនចេញទៅរកសេចក្ដីសុខធំទូលាយទេ សត្វលោកនោះទុកដូចជាជ្រូកស្រុក ដែលគ្រាំនៅក្នុងជ្រាំ ដល់ពេលវេលាត្រូវគេនាំទៅកាន់ទីសត្តឃាត ។ សត្វលោកណាមានប្រាជ្ញាមើលឃើញលោកនេះជាភ្លើង មិនស៊ូដេកគ្រាំពេកទេ តែងរំរកឧបាយគេចចេញពីទុក្ខក្នុងលោកភ្លើងនេះ សត្វនោះដូចលលកជាប់ទ្រុង ចេះតែយកចំពុះចឹកលបែងសទ្រុងគ្រប់ពេលរកច្រកល្ហក រកឧបាយរើខ្លួនស្ទុះឲ្យរួចពីទ្រុងគឺទុក្ខជានិច្ច ។ ច្រកដែលយើងត្រូវគេចឲ្យរួចផុតពីទុក្ខក្នុងលោកនេះមានតែមួយទេ គឺបុណ្យនេះឯង ផ្លូវដទៃទៀតមិនមានឡើយ ។ អ្នកដែលមិនមែនជាពុទ្ធសាសនិកជន មិនស្គាល់បុណ្យ មិនស្គាល់ហេតុនាំឲ្យកើតបុណ្យ រមែងស្អប់បុណ្យណាស់ ព្រោះគេថាបុណ្យដូចជាយកឈើស្ទូលទៅដាក់រន្ធត្រចៀក សូម្បីពុទ្ធសាសនិកជន ដែលមានការចេះដឹង

ពុទ្ធសាសនាតិច ក៏មិនអាចនឹងស្គាល់បុណ្យជាក់ច្បាស់លាស់ដែរ ព្រោះបុណ្យជាចេតសិកធម៌កើតអាស្រ័យមួយអន្លើដោយចិត្ត មិនអាចយកមកបង្ហាញឲ្យឃើញច្បាស់ដូចជាគេបង្ហាញរូបថា នេះស្រី នេះប្រុស ឬបង្ហាញពណ៌ថានេះស-ខ្មៅ-ក្រហម បានឡើយ ។

តាមរូបសព្ទ ធម្មជាតដែលធ្វើសន្តានចិត្តឲ្យបរិសុទ្ធឬជំរះសន្តានចិត្តឲ្យជ្រះថ្លាស្អាតលោកហៅថាបុណ្យ ។ តាមអត្ថាធិប្បាយ, ការបំពេញកុសល ការប្រព្រឹត្តិធ្វើអំពើល្អឬសេចក្ដីសុខ លោកហៅថាបុណ្យ ។ បុណ្យនេះជាចេតសិកធម៌កើតរលត់មួយអន្លើដោយចិត្ត ខណៈចិត្តកើតឡើងចិត្តជាបុណ្យក៏កើតឡើង, ខណៈចិត្តរលត់ ចិត្តជាបុណ្យក៏រលត់ទៅវិញ ។ កិច្ចការទាំងពួងរមែងមានចិត្តជាប្រធាន មានចិត្តទៅដល់មុន មានចិត្តជាគ្រឿងប្រសើរ សម្រេចហើយដោយចិត្ត ។ ចិត្តជាប្រក្រតីឬចិត្តដែលមិនទាន់មានឧបក្កិលេសចូលទៅប្រទូស្ត ជាបកតិមនោឬភវង្គចិត្តជាធម្មជាតភ្លឺផ្លេក ។ ភវង្គចិត្តនេះ កាលបើមានឧបក្កិលេសចូលទៅធ្វើឲ្យសៅហ្មង ក៏ប្រែក្លាយទៅជាចិត្តសៅហ្មង កាលបើគុណធម៌ចូលទៅធ្វើឲ្យជ្រះថ្លា ក៏ត្រឡប់ទៅជាចិត្តជ្រះថ្លា ។ ចិត្តអាក្រក់ បើនឹងធ្វើនឹងនិយាយ នឹងគិត ក៏ផ្អៀងទៅរកតែខាងអាក្រក់, ចិត្តល្អ បើនឹងធ្វើនឹងនិយាយ នឹងគិត ក៏ដើរទៅចំលើល្អ ។ ហេតុនេះ ចិត្តជាល្ខោនតួឯកដ៏សំខាន់បំផុតដែលចេញមកពាំនាំឆាកគឺជីវិតយើងនេះ ។ អ្នកប្រាជ្ញ

ទាំងឡាយ មានព្រះពុទ្ធជាដើម បានត្រាស់ទូវអំណាចចិត្តយ៉ាងនេះឯងហើយ ទើបចាប់ប្រារព្ធពត់ចិត្ត ទូន្មានចិត្តមុនជាងអ្វីទាំងពួង, លោកយកសតិសម្បជញ្ញៈ ទុកជាសារថីឬឆ្មាំទ្វារ ឃុំចាំមើលចិត្ត ដាស់តឿនរំឭកចិត្តជានិច្ចនិរន្តរ៍គ្រប់ខណៈចិត្ត កៀងចិត្តឲ្យដើរត្រង់ទៅរកសេចក្ដីល្អ មិនឲ្យជ្រុលឬផ្អៀងទៅរទន់ទៅរកអាក្រក់សោះ ព្រោះថាបើបានទូន្មានចិត្តបានបទហើយ ទើបបានបុណ្យគឺសេចក្ដីសុខ ។

អ្នកប្រាថ្នាបុណ្យ មិនចេះដឹងពុទ្ធសាសនា មិនអាចធ្វើបុណ្យឲ្យបានត្រឹមត្រូវតាមគន្លងធម៌ទេ ព្រោះការបំពេញបុណ្យនេះ មានច្បាប់មានខ្នាតបន្ទាត់មត់ចត់ល្អណាស់ មិនមែនធ្វើហើយចេះតែបានបុណ្យទេ ។ ប្រទេសយើង ជាប្រទេសកាន់ព្រះពុទ្ធសាសនា ប្រជាជនខ្មែរទាំងមូលសុទ្ធតែជាពុទ្ធសាសនិក តែការចេះដឹងពុទ្ធសាសនានៅទន់ខ្សោយពេក ហេតុនេះហើយ បានជាមានឃើញការភ័ន្តច្រឡំច្រើនប្រការណាស់ក្នុងការបំពេញកុសល ។ តាមវត្តអារាមនៅមានភិក្ខុសាមណេរ សូត្រធម៌ជាភាសាបាលីវៀងឃ្លាតអក្ខរព្យញ្ជនៈ មានខ្លះសូត្រតែបាត់ព្យញ្ជន ឮសូរតែសម្លេងចេញមកស្ដាប់សេចក្ដីមិនបាន, ការសូត្រដូច្នេះដូចសត្វនិយាយភាសាមនុស្ស ។ ការបំពេញកុសល ទាន សីល សមាធិ បញ្ញា ច្រើនតែធ្វើទៅតាមទំនៀមទំលាប់ដែលធ្លាប់ធ្វើមក ហើយវៀងឃ្លាតពីច្បាប់ស្ទើរតែមិនបានត្រឹមត្រូវសោះ ។ នេះជាអំពើនាំឲ្យពុទ្ធសាសនាថោក

តាមទន់ខ្សោយទៅវិញ ។ អ្នកដែលជ្រះថ្លាហើយនឹងបាត់សេចក្ដីជ្រះថ្លាទៅវិញ អ្នកមិនទាន់ជ្រះថ្លានឹងជ្រះថ្លាមិនកើត ហើយជាផ្លូវមួយនាំឲ្យអ្នកផងទាំងពួងគេមើលងាយដល់ពុទ្ធសាសនាផង ។ ធម៌ក្នុងពុទ្ធសាសនាដែលអ្នកប្រាជ្ញល្អត្រូវប្រតិបត្តិដើម្បីឲ្យបានបុណ្យនោះ លោករួមមកនៅត្រឹម ៤ ប្រការគឺ ទាន ១ សីល ១ សមាធិ ១ បញ្ញា ១ ។ អ្នកឲ្យទាន, អ្នករក្សាសីល, អ្នកធ្វើសមាធិភាវនា, អ្នកធ្វើបញ្ញាភាវនា ឈ្មោះថាអ្នកធ្វើបុណ្យទាំងអស់ ។ នៅប្រទេសយើង អ្នកផងទាំងពួងយល់ថា “អ្នកឲ្យទាន ដូចធ្វើកុដិ ធ្វើផ្កា ធ្វើកឋិន ធ្វើសីមា ធ្វើពុទ្ធាភិសេកជាដើម ទើបឈ្មោះថាធ្វើបុណ្យ”, ឯការបំពេញភេទជាបព្វជិត, ការរក្សាសីល, ស្តាប់ធម៌ទេសនា, ការធ្វើសមាធិភាវនានឹងបញ្ញាភាវនា, គេមិនសូវយល់ឃើញថាជាការធ្វើបុណ្យទេ; សេចក្ដីពិតពុំមែនដូច្នោះទេឡើយ, ការបំពេញធម៌ទាំង ៤ ប្រការគឺ ទាន សីល សមាធិ បញ្ញា នេះឈ្មោះថាធ្វើបុណ្យ ។ មួយទៀត, ការកសាងសាលារៀន, មន្ទីរពេទ្យ, សង់ស្ពាន, ជីកអណ្ដូង, ជីកស្រះសំរាប់ប្រទេសជាតិ, ការទូន្មានប្រដៅកុមារ កុមារី ឲ្យមានសីលធម៌ល្អ ទាំងអស់នេះ គេច្រើនតែមិនជឿថាជាការធ្វើបុណ្យទេ ។ ទាំងនេះមកពីយើងមិនសូវស្គាល់ពុទ្ធសាសនា ។ ការធ្វើកុដិ, ផ្កា, កឋិន, សីមា, ពុទ្ធាភិសេក: សង់សាលារៀន, មន្ទីរពេទ្យ, ស្ពាន, ជីកអណ្ដូងស្រះ ទាំងអស់នេះរួមចូលទៅក្នុងទាន ។ នៅប្រទេសយើង, អ្នកផងទាំងពួង

ចូលចិត្តធ្វើទាន សីល សមាធិ បញ្ញា ជាវិវដ្តគាមិនី មិនសូវពេញចិត្តធ្វើជាវិវដ្តគាមិនីទេ ៗ ឯការរក្សាសីល, ការធ្វើសមាធិភាវនា, បញ្ញាភាវនាក៏នៅទន់ខ្សោយណាស់ ៗ ការបំពេញកុសលជាវិវដ្តគាមិនី ជាធម៌ដែលព្រះពុទ្ធទ្រង់សរសើរបំផុត ៗ ក្នុងពុទ្ធសាសនានេះ សារៈសំខាន់មានតែមួយ គឺការទូន្មានចិត្ត កសាងចិត្ត ៗ ឯវិធីកសាងចិត្តមានច្រើនយ៉ាងណាស់ ព្រោះចិត្តជាធម្មជាតដែលគេពិបាកទូន្មាន ទើបលោកត្រូវចាប់ផ្តើមទូន្មានចិត្តតាំងពីការសន្សំបុណ្យគឺការឲ្យទាន, រក្សាសីលជាដើមឡើងទៅ រហូតទៅដល់ធ្វើសមាធិពត់ចិត្ត ហើយធ្វើបញ្ញាភាវនាប្រមូលបញ្ញាមកធ្វើជាពលច្បាំង តស៊ូកិលេសទាំងពាន់ហារយឲ្យផុតចេញចាកសន្តានចិត្ត ដូចព្រះដម្រាស់ថា "អ្នកកាន់ពុទ្ធសាសនា គឺអ្នកប្រាថ្នាបុណ្យនេះជាអ្នកចំបាំងមួយ តាំងព្យាយាមច្បាំងតស៊ូចំពោះកិលេសច្បាំងមិនឈប់ឈរផកបដល់ឈ្នះកិលេស ហើយមិនត្រឡប់ចាញ់វិញ" ៗ

អ្នកប្រាថ្នាបុណ្យ កាលបំពេញកុសលណាមួយ គួរតាំងចិត្តជាកុសលជាធម្មាធិបតេយ្យ ជាវិវដ្តគាមិនី ជាបារមី សោមនស្ស ជាញាណ-សម្បយុត្តអសំខារិក, បុរសស្ត្រីណាមួយ បានញុំាងចិត្តឲ្យប្រព្រឹត្តទៅតាមដំណើរដែលពោលមកនេះនឹងបានបុណ្យជាទិដ្ឋធម្មវេទនីយ៍ ច្រើនជាងដំណើរចិត្តជាកុសលឯទៀត ៗ ដំណើរចិត្តជាមហាកុសល តាមអភិធម្មត្ថសង្គហៈ លោកពោលថាមាន ៨ ប្រការគឺ :

១ – ចិត្តកើតព្រមដោយសោមនស្ស ជាញាណសម្បយុត្ត អសំខារិក;

២ – ចិត្តកើតព្រមដោយសោមនស្ស ជាញាណសម្បយុត្ត សសំខារិក;

៣ – ចិត្តកើតព្រមដោយសោមនស្ស ជាញាណវិប្បយុត្ត អសំខារិក;

៤ – ចិត្តកើតព្រមដោយសោមនស្ស ជាញាណវិប្បយុត្ត សសំខារិក;

៥ – ចិត្តកើតព្រមដោយឧបេក្ខា ជាញាណសម្បយុត្ត អសំខារិក;

៦ – ចិត្តកើតព្រមដោយឧបេក្ខា ជាញាណសម្បយុត្ត សសំខារិក;

៧ – ចិត្តកើតព្រមដោយឧបេក្ខា ជាញាណវិប្បយុត្ត អសំខារិក;

៨ – ចិត្តកើតព្រមដោយឧបេក្ខា ជាញាណវិប្បយុត្ត សសំខារិក ។

អ្នកធ្វើកុសល អនុវត្តចិត្តឲ្យដើរទៅតាមគន្លងកុសលចិត្តទាំង ៨ ប្រការនេះ នឹងបានកុសលច្រើន ជាទិដ្ឋធម្មវេទនីយ៍ ជាឧបបជ្ជវេទនីយ៍ ជាអបរាបរិយវេទនីយ៍ ទៅតាមកម្លាំងទឹកចិត្តដែលកើតឡើង ។ ចូឡេក-សាដកព្រាហ្មណ៍ កាលបូជាសំពត់សាដកថ្វាយព្រះសម្មាសម្ពុទ្ធ អនុវត្តចិត្តទៅតាមគន្លងមហាកុសលចិត្តទីមួយ គឺថា “ចិត្តកើតព្រមដោយសោមនស្ស ជាញាណសម្បយុត្ត អសំខារិក” គឺចូឡេកសាដកព្រាហ្មណ៍ផ្គងចិត្តជាធម្មាធិបតេយ្យយកធម៌ជាធំ មិនមែនជាអត្តាធិបតេយ្យយកខ្លួនជាធំ ឬលោកាធិបតេយ្យយកលោកជាធំ តាំងចិត្តរើខ្លួនចេញចាកវដ្ដៈ មានសោមនស្សត្រេកត្រា ប្រកបដោយប្រាជ្ញាពិចារណារកហេតុផល មិនមានអ្នកណាមួយមកណែនាំពន្យល់ លើកសំពត់សាដកបូជា ក្នុងពេលដែលចិត្តតាំងនៅយ៉ាងនេះ ។

តាមសេចក្តីដំណាលថា “មានព្រាហ្មណ៍ម្នាក់ឈ្មោះចូឡេកសាដក ជាព្រាហ្មណ៍ក្រីក្រ មានតែសាដកមួយសំពត់ប្រើផ្លាស់ប្តូរ បើស្វាមីប្រើសាដក ភរិយាត្រូវនៅក្នុងផ្ទះ បើភរិយាប្រើ ស្វាមីត្រូវនៅក្នុងផ្ទះ ។ ថ្ងៃមួយមានការឃោសនាទៅស្តាប់ព្រះធម្មទេសនាព្រះសម្មាសម្ពុទ្ធ ព្រាហ្មណ៍ប្រឹក្សានឹងព្រាហ្មណីថា “នាងអើយ ! នាងទៅស្តាប់ធម៌ពេលថ្ងៃ ឬពេលយប់ យើងទៅទាំងពីរនាក់មិនបាន ព្រោះយើងគ្មានសាដកសំពត់ដណ្តប់ ។ នាងព្រាហ្មណីឆ្លើយថា “ខ្ញុំទៅពេលថ្ងៃ” ។ ពេលយប់ព្រាហ្មណ៍ទៅស្តាប់ធម៌ ។ ព្រាហ្មណ៍នៅអង្គុយចំពោះព្រះភក្ត្រព្រះសម្មាសម្ពុទ្ធ កើតបីតិមានពណ៌ ៥ ប្រការ ផ្សាយពេញសរីរៈ គំនិតចង់បូជាសាដក ។ ក្នុងខណៈនោះមានគំនិតមួយកើតឡើងគិតថា បើបូជានាងព្រាហ្មណីឥតសាដកដណ្តប់ ក៏រេរាគិតចុះគិតឡើងច្រើនដងច្រើនគ្រា ។ កាលនោះ កើតសង្គ្រាមធំឡើង គឺមច្ឆរិយចិត្តមួយពាន់កើតឡើងប្រឆាំងតទល់នឹងសទ្ធាចិត្ត ។ សទ្ធាចិត្តកើតឡើង សង្កត់មច្ឆរិយចិត្តជាប់ បន្តិចទៀត មច្ឆរិយចិត្តរើប ហើយសង្កត់សទ្ធាចិត្តវិញ ចិត្តទាំងពីរនេះកើតរលត់ត្រឡប់ផ្កាប់ផ្ងារ សង្កត់គ្នាទៅវិញទៅមកយ៉ាងនេះ អស់បឋមយាម ។ លុះមជ្ឈិមយាមកន្លងទៅទៀត ចិត្តទាំងពីរក៏នៅកំពុងប្រឆាំងជាញជ័យគ្នាមិនទាន់ដាច់ស្រេចទៀត ។ ទីបំផុត, ក្នុងបច្ឆិមយាម ទើបសទ្ធាចិត្តចាប់សង្កត់មច្ឆរិយចិត្តជាប់មិនឲ្យកើតឡើងបានទៀត សទ្ធាចិត្តមានជ័យ

ព្រាហ្មណ៍ក៏ក្រោកកាន់យកសាដក ដើរចូលទៅថ្វាយព្រះសម្មាសម្ពុទ្ធ ស្រែកខ្លាំងៗ ដល់ទៅ ៣ ដងថា "ឈ្នះហើយៗ" ។ ពេលនោះ, ព្រះបាទបសេនទិកោសល ស្ដេចកំពុងប្រថាប់ទ្រង់ព្រះសណ្ដាប់ក្នុងទីនោះដែរ ទ្រង់សួរដឹងប្រព្រឹត្តិការណ៍ តាំងពីដើមដល់ចុង ទ្រង់ជ្រះថ្លា ទើបប្រទានសាដកមួយគូដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍យកសាដកមួយគូនោះថ្វាយព្រះសម្មាសម្ពុទ្ធ ។ ព្រះរាជាប្រទានពីរគូ បួនគូ ដប់ប្រាំ-មួយគូ ព្រាហ្មណ៍ថ្វាយព្រះសម្មាសម្ពុទ្ធទាំងអស់ទៀត ។ ព្រះរាជាប្រទាន ៣២ គូ, ព្រាហ្មណ៍យកពីរគូទុក មួយគូដើម្បីខ្លួន មួយគូទៀតទុកដើម្បីភរិយា សល់ ៣០ គូបូជាព្រះសម្មាសម្ពុទ្ធទាំងអស់, តមក ព្រះរាជាប្រទានកម្ពល ២ ដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍យកកម្ពលទាំងពីរនោះថ្វាយព្រះសម្មាសម្ពុទ្ធ មួយបង់ជាពិតានទុកថ្វាយទៅគន្ធកុដិ មួយទៀតបង់ជាពិតានទៅពុទ្ធាសនះក្នុងផ្ទះខ្លួន ។ ព្រះរាជាទ្រង់ជ្រាប, ទ្រង់ជ្រះថ្លា ហើយប្រទានដំរី ៤, សេះ ៤, ពាន់កហាបណៈ ៤, ស្ត្រី ៤, ទាសី ៤, បុរស ៤, ស្រុកសួយ ៤, ទ្រង់ប្រទានក្នុងមួយមុខៗ តែបួនៗ យ៉ាងនេះរហូតដល់មួយរយមុខ ។ តមក, មានពាក្យពោលសរសើរក្នុងធម្មសភាអឺងកងថា "អស្ចារ្យណាស់ហ្ន៎! បូឡុកសាដកបេះធ្វើកុសលកម្ម បានផលជាទិដ្ឋធម្មវេទនីយ៍ ហើយបានតែមួយមុខបួនៗ ។ ព្រះបរមសាស្ដាស្ដេចយាងមកដល់ត្រាស់សួររួចហើយសំដែងថា "ម្នាល

ភិក្ខុទាំងឡាយ! ប្រសិនបើចូឡេកសាដកនេះ អាចនឹងបូជាតថាគតក្នុងបឋមយាម គាត់នឹងបានវត្ថុមួយមុខៗ ១៦; បើក្នុងមជ្ឈិមយាម នឹងបានវត្ថុមួយមុខៗ ៨ តែនេះគាត់ចាំរក្សាសទ្ធាចិត្តដែលកើតឡើងមិនឲ្យបាត់ទៅវិញ ហើយឲ្យក្នុងបច្ចិមយាមទើបបានជាគាត់បានវត្ថុមួយមុខៗ ២ ប៉ុណ្ណោះ, កុសលកម្មដែលគេធ្វើយឺតយូរ ផលឲ្យសម្បត្តិក៏យឺតយូរ, ព្រោះហេតុនោះ កល្យាណកម្មបុគ្គលគប្បីធ្វើភ្លាមៗ ក្នុងលំដាប់នៃខណចិត្តដែលកើតឡើង, មានព្រះពុទ្ធដីកាដូច្នេះហើយត្រាស់ព្រះសទ្ធម្មទេសនាជាគាថាដូច្នេះថា :

“ បុគ្គលគប្បីរវៀសរវៃធ្វើនូវកល្យាណកម្ម ហើយឃាត់ចិត្តបាបកុំឲ្យកើតឡើងបាន ព្រោះថា កាលបើបុគ្គលធ្វើដោយយឺតយូរ ចិត្តឈ្មោះថា ត្រេកអរក្នុងបាប ” ។

បុគ្គលបំពេញកុសល ទាន សីល សមាធិ ឬ បញ្ញា ដែលហៅថាធ្វើបុណ្យ អាចកំណត់ដឹងបុណ្យបានដោយផ្លូវចិត្ត ព្រោះបុណ្យកើតក្នុងចិត្ត ៗ ក្នុងពេលកំពុងធ្វើនឹងដឹងក្នុងផ្លូវចិត្ត ៗ ការដឹងថាបុណ្យនេះនិយាយជាភាសាមនុស្សមិនចេញមែន តែគេអាចដឹងបានដូចជាគេដឹងរសជាតិអាហារឆ្ងាញ់ដែលគេកំពុងបរិភោគ អ្នកបរិភោគដឹងថាឆ្ងាញ់ តែយកចំណាញ់នោះមកបង្ហាញមិនបានយ៉ាងណា បុណ្យយ៉ាងនោះដែរ ៗ ចិត្តរីករាយរីកថ្លើមប្រមាត់ កើតបីតិបាមោជ្ជព្រឺរោមព្រឺស្បែក ទឹកមុខឡើង

ថ្លាត្រយង់ស្រស់បំព្រង ដូចទឹកមុខស្រស់នៃកុមារតូចៗដែលញញឹម នេះជាលក្ខណៈនៃចិត្តបុណ្យ ។ តែកុំច្រឡំការរីករាយក្នុងផ្លូវកាម ។ ការរីករាយតាមសេចក្ដីជាភាសាខ្មែរមានច្រើន, ការមើលកុនល្ខោនរាំច្រៀងមានការរីករាយសប្បាយម្យ៉ាង តែរីករាយសប្បាយនេះជាផ្លូវកាម រីករាយក្ដៅមិនត្រជាក់ទេ ទឹកមុខក្រហមឆេះដោយកាម ។ ការរីករាយបុណ្យ រីករាយត្រជាក់ ឆ្អែតកាយឆ្អែតចិត្ត មិនមែនសប្បាយសើចហាសហាយទេ រីករាយញញឹមស្រស់បំព្រង ត្រេកអរម្នាក់ឯងតែក្នុងផ្លូវចិត្ត ហាក់ដូចជាអណ្ដែតខ្លួន មិនងងុយដេក មិនខ្ជិលច្រអូសកាយ មានកម្លាំងក្លៀវក្លាដូចទុគ្គតបុរសនឹងភរិយា ទៅស៊ីឈ្នួលពុះអុសនឹងបុកអង្ករឲ្យសេដ្ឋីយកកម្រៃទៅធ្វើទាន ត្រេកអរខ្លាំងណាស់ សូម្បីដល់ស្លាប់ខ្លួនក៏មិនខ្លាច កាន់បុណ្យជាទីពឹង ព្រោះយល់ច្បាស់ថា "បើស្លាប់ក៏បានសុខ" ដូចអ្នកនយោបាយ នឿយលំបាកក៏សុខចិត្ត ព្រោះបានប្រទេសចំរើន ។

ក្នុងពុទ្ធសាសនានេះ លោកចែកបុណ្យជា ២ ប្រភេទ គឺ បុណ្យជាហេតុ ១ បុណ្យជាផល ១ ។ ការបំពេញកុសល គឺ ការឲ្យទាន រក្សាសីល ធ្វើសមាធិភាវនា ធ្វើបញ្ញាភាវនា បង្កបង្កើតជាបច្ច័យឲ្យបានកើតជាបុណ្យឡើង ហៅថាបុណ្យជាហេតុ ។ ផលានិសង្សដែលត្រូវបានពីការបំពេញកុសលទាំងឡាយនោះៗ គឺបានភាពជាមនុស្សមានរូបល្អ មានភោគទ្រព្យ បានជាស្ដេចមានយសបរិវារ បានជាទេវបុត្រទេវតា រហូតដល់ទៅបានជា

ព្រះអរិយជនគឺព្រះវីណា ស្រេចជាទីបំផុត លោកហៅថាបុណ្យជាផល ។ បើយើងផ្ចង់គិតមើលទៅពិភពលោកដ៏ធំទូលាយនេះ យើងនឹងឃើញថា សត្វលោកទាំងមូលប្លែកគ្នា ជនខ្លះរូបអាក្រក់ ជនខ្លះរូបល្អ ជនខ្លះក្រីក្រ ជនខ្លះមានទ្រព្យសម្បត្តិ ជនខ្លះល្ងង់ខ្លៅ ជនខ្លះទៀតមានប្រាជ្ញា ។ តាមព្រះពុទ្ធសាសនា ថាការប្លែកគ្នាទាំងនេះប្រាកដជាមកពីកម្មជាអកុសល ឬ កុសលដែលសត្វទាំងឡាយនោះៗ បានធ្វើហើយ មិនមែនមកពីកើតមានឯកឯងទេ ដូចព្រះពុទ្ធដីកាត្រាស់ថា : “កម្មជាបុណ្យជាបាបនេះឯង ចែកសត្វទាំងឡាយឲ្យទៅជាអាក្រក់ទៅជាល្អ” ។ ក្នុងចូឡកម្មវិភង្គសូត្រ ព្រះសម្មាសម្ពុទ្ធទ្រង់ដោះអាថ៌ប្រស្នា ១៤ ប្រការ ដែលសុភមាណពតោទេយ្យបុត្រ ក្រាបទូលសួរដោយសេចក្ដីពិស្ដារ ទ្រង់ត្រាស់ថា សត្វទាំងឡាយ មានកម្មជារបស់ខ្លួន ជាមត៌ក ជាកំណើត ជាពន្ធុ ជាទីពឹង កម្មនេះឯង ចែកសត្វទាំងឡាយឲ្យទៅជាអាក្រក់ ឲ្យទៅជាល្អ គឺ ១– សត្វអាយុខ្លី ព្រោះទោសបាណាតិបាត; ២– សត្វអាយុវែង ព្រោះវៀរចាកបាណាតិបាត; ៣– សត្វឈឺច្រើន ព្រោះទោសហឹសាការបៀតបៀនជនដទៃ; ៤– សត្វមិនសូវឈឺ ព្រោះអហឹសាការមិនបៀតបៀនជនដទៃ; ៥– សត្វមានពណ៌អាក្រក់ ព្រោះក្រោធច្រើន; ៦– សត្វមានពណ៌ល្អ ព្រោះការវៀរចាកក្រោធ; ៧– សត្វមិនមានបុណ្យសក្តិ ព្រោះទោសឥស្សា; ៨– សត្វមានបុណ្យសក្តិ

ព្រោះវៀរចាកឥស្សា ; ៩– សត្វក្រីក្រ ព្រោះការមិនឲ្យទាន; ១០– សត្វមានទ្រព្យ ព្រោះការឲ្យទាន; ១១– សត្វកើតក្នុងត្រកូលថោកទាប ព្រោះប្រកាន់មានះ; ១២ – សត្វកើតក្នុងត្រកូលខ្ពង់ខ្ពស់ ព្រោះមិនប្រកាន់មានះ: ១៣ – សត្វឥតប្រាជ្ញា ព្រោះមិនសាកសួរមិនសិក្សាឲ្យស្គាល់ខុសត្រូវ: ១៤ – សត្វមានប្រាជ្ញា ព្រោះការសាកសួរសិក្សារៀនសូត្រ ៗ កម្មជាបុណ្យជាបាបនេះ ដែលនឹងសម្រេចផលល្អអាក្រក់ កើតប្រាកដក្នុងលោកនេះ ក៏ត្រូវអាស្រ័យហេតុគឺការព្យាយាមធ្វើក្នុងបច្ចុប្បន្ននេះផង ៗ កម្មទោះជាអកុសលក្តី ទោះជាកុសលក្តី ដែលសត្វបានធ្វើហើយ ត្រូវត្រឡប់បានផលវិញ បើទុកជាសត្វដែលធ្វើមិនចង់បាន ក៏ត្រូវតែបាន ព្រោះមានហេតុជាបច្ច័យ, ហេតុនេះជាបច្ច័យឲ្យកើតផល កម្មពីអតីតឲ្យផលមកក្នុងបច្ចុប្បន្ន កម្មក្នុងបច្ចុប្បន្នឲ្យផលទៅអនាគត ជាបច្ច័យត ៗ គ្នាយ៉ាងនេះរហូតតទៅ លុះត្រាតែមិនមានហេតុ ទើបមិនតឲ្យមានផល ៗ ហេតុនេះហើយបានជាក្នុងពុទ្ធសាសនា លោកសំដែងថា កុំឲ្យធ្វើកុសលណាមួយហើយ តាំងចិត្តប្រាថ្នាទ្រព្យក្នុងលោកនេះ ការមិនតាំងចិត្តប្រាថ្នាទ្រព្យក្នុងលោកនេះ លោកហៅថា វិវដ្តគាមិនីកុសល គឺកុសលដែលនាំឲ្យរួចពីទុក្ខគឺវដ្តសង្សារនេះ ដើម្បីផ្តាច់កុំឲ្យមានបច្ច័យតទៅអនាគត ឲ្យសល់នៅតែកិរិយាដូចព្រះអរហន្តខីណាស្រព មិនមានបុណ្យបាបតទៅទៀត ៗ

សត្វទាំងឡាយចង់បានសេចក្ដីសុខ តែចង់បានដោយមិនចាំបាច់ធ្វើអ្វី ៗ មិនដែលមាន ! សេចក្ដីសុខបានមកឯកឯងដូចជាបកបោយ ៗ អ្វីទាំងអស់ សុទ្ធតែបានដោយធ្វើ ។ ឯសេចក្ដីសុខក៏បានដោយធ្វើ តែមិនមែនចេះតែធ្វើបានទេ ចង់បានសុខទៅបួងសួងបន់ស្រន់ព្រៃភ្នំគ្រឹះព្រៃព្រឹក្សា ចេតិយ វិហារ មិនបានសេចក្ដីសុខទេ ៗ មួយទៀត, នរជនដោយច្រើនស្មើតែទាំងអស់ យល់ថាសេចក្ដីសុខកើតនៅក្នុងទ្រព្យសម្បត្តិដែលជាប់នៅលើផែនដីនេះ ហេតុនេះហើយ បានជាឃើញមានជនស្ទើរតែទ្រព្យសម្បត្តិមាសប្រាក់ជាដើម ខ្វះហ៊ានរករហូតដល់ប្រចុយខ្លួនស្លាប់ទីងទ្រព្យនោះៗ ៗ ព្រះពុទ្ធជាម្ចាស់ទ្រង់មិនបដិសេធទេ ទ្រង់ទទួលស្គាល់ថា ទ្រព្យជាសេចក្ដីសុខពិត ទ្រង់ឲ្យឈ្មោះថា សេចក្ដីសុខកើតពីទ្រព្យសម្បត្តិ តែសេចក្ដីសុខនេះមិនទៀងទាត់ទេ ៗ តាមការពិចារណា, ទ្រព្យសម្បត្តិមិនមែនសុទ្ធតែឲ្យសុខទេ ទ្រព្យជារបស់អព្យាក្រិត ធ្វើឲ្យបានសុខ ឬឲ្យបានទុក្ខ ស្រេចតែពីអ្នកម្ចាស់ទ្រព្យ ៗ អ្នកម្ចាស់ទ្រព្យកំណាញ់លុងអាប់ឥតប្រាជ្ញា ទ្រព្យឲ្យទុក្ខ ដូចធ្យូងគ្រាន់តែឲ្យប្រឡាក់ដៃ, ទ្រព្យដែលរកបានមកដោយលំបាក មិនបានជាប្រយោជន៍ផ្ដល់សេចក្ដីសុខសំរាប់ខ្លួនទីងជនទូទៅ មិនមែនតែប៉ុណ្ណោះទេ មនុស្សកំណាញ់មានទោសធ្ងន់តទៅទៀត ព្រោះសត្វមានលោភចិត្តជាប់ជំពាក់ចំពោះទ្រព្យជាធម្មតា ដល់ធ្វើមរណកាលទីងទៅកាន់

អបាយភូមិដោយលោភចិត្តនេះឯង ទៅកើតជាតិណាទៀត រូបអាក្រក់ ក្រីក្រហេមហាមថែមទៀត ដូចអានន្ទសេដ្ឋីមានទ្រព្យប៉ែតសិបកោដិ កំណាញ់មិនធ្វើទាន ស្លាប់ទៅៗកើតជាកូនជនចណ្ឌាល កាន់អំបែងដើរសូមទានគេត្រដាបត្រដួសស្ទើរតែនឹងរស់នៅមិនបាន ។ អ្នកម្ចាស់ទ្រព្យមានសទ្ធា មានប្រាជ្ញាឆ្លៀវឆ្លាត មានទ្រព្យទើបបានសេចក្ដីសុខ ទ្រព្យសម្បត្តិដែលរកបានមកដោយលំបាក ទើបបានជាប្រយោជន៍ផ្ដល់សេចក្ដីសុខសំរាប់ខ្លួននឹងសំរាប់ជនទូទៅ ដល់ធ្វើមរណកាលទៅកាន់បរលោក ទ្រព្យនេះជាបច្ច័យឲ្យសេចក្ដីសុខទូលំទូលាយវែងឆ្ងាយទៅទៀត ។ មួយទៀត, ទ្រព្យសម្បត្តិនេះ សូម្បីមាននៅក្នុងផ្ទះយើងក៏មិនសុទ្ធតែឲ្យសុខយើង ជួនកាលឲ្យសេចក្ដីទុក្ខដល់យើងផង ព្រោះទ្រព្យសម្បត្តិមានលាយធម្មជាតិមិនទៀងទាត់ បាក់បែក ប្រែះឆា ចោរលួច_វិនាសបាត់បង់ ជាសេចក្ដីទុក្ខកើតពីកំណើតទ្រព្យស្រាប់ដូចលោកពោលថា កាលរកលំបាកម្ដង បានមកហើយលំបាករក្សាម្ដង ដល់បាត់បង់ទៅវិញលំបាកម្ដងទៀត ។ ហេតុនេះ ក្នុងការស្វែងរកសេចក្ដីសុខ អ្នកប្រាជ្ញមានភ្នែកមើលឃើញច្បាស់យល់ថា ត្រូវយកទ្រព្យឥតខ្លឹមសារប្ដូរឲ្យទៅជាទ្រព្យមានខ្លឹមសារទៀងទាត់ ជាអរិយទ្រព្យ ដូចសេចក្ដីដែលព្រះសម្មាសម្ពុទ្ធសំដែងទុកថា “ កាលបើផ្ទះត្រូវភ្លើងឆាបឆេះ ជនម្ចាស់ផ្ទះតែងជញ្ជូនទ្រព្យសម្បត្តិមានភាជនៈជាដើមចេញអំពីផ្ទះ ទ្រព្យណាដែល

គេប្រញាប់ដញ្ជូនចេញផុត ភ្លើងឆេះមិនបាន ទ្រព្យនោះរមែងបានទៅជាប្រយោជន៍របស់គេទៅយ៉ាងណា សត្វលោកដែលត្រូវភ្លើងគឺជរា ព្យាធិមរណៈឆាបឆេះ គួរប្រញាប់ដញ្ជូនចេញឲ្យផុតអំពីផ្ទះគឺកាយ ដោយការឲ្យទាន ព្រោះទានដែលគេឲ្យហើយនោះឯង ឈ្មោះថាបានដញ្ជូនទ្រព្យទុកដោយល្អ មិនឲ្យភ្លើងឆេះបានយ៉ាងនោះឯង ៗ ផ្ទះគឺអត្តភាពនេះ ដែលត្រូវភ្លើងគឺមរណៈបៀតបៀនហើយរលត់រលាយទៅ តែកុសលដែលយើងបានធ្វើទៅជាអរិយទ្រព្យ ជាទ្រព្យផុតពីភ្លើងឆេះហើយ នឹងបានជាបុញ្ញាភិសង្ខារកសាងអត្តភាពរូបកាយយើងនេះ ឲ្យបានជាមនុស្សមានរូបល្អ ជាទេពតា នឹងជាមនុស្សសម្បត្តិ ទេវតាសម្បត្តិព្រមទាំងនិព្វានសម្បត្តិ ៗ មួយទៀត, នរជនកប់ទ្រព្យទុកក្នុងដីដោយគិតថា "កាលណាមានអន្តរាយកើតឡើង ដោយព្រះរាជអាជ្ញាក្ដី ដោយចោរបៀតបៀននឹងទុព្ភិក្ខភ័យជាដើមក្ដី ទ្រព្យនេះនឹងបានជាប្រយោជន៍ដោះក្ដីអន្តរាយនោះៗ" គំនិតនេះ មិនមែនសុទ្ធតែបានសម្រេចសព្វ ៗ កាលទេ ព្រោះទ្រព្យនោះរផាត់រទាំងក៏មាន ភ្លេចចោលក៏មាន ចោរលួចយកក៏មាន បាត់បង់ទៅដោយហេតុផ្សេងៗក៏មាន ពុំនោះខ្លួនយើងស្លាប់ចោលទៅក៏មាន ដូច្នេះ កំណប់ទ្រព្យនោះមិនប្រសើរទេ ៗ កំណប់ទ្រព្យគឺទាន សីល សមាធិ បញ្ញា ដែលបុរសស្ត្រីបានធ្វើហើយ ក្នុងបុគ្គលគួរគោរព ក្នុងសង្ឃ ក្នុងភ្ញៀវ ក្នុងមាតាបិតា ក្នុងត្រកូលរៀមច្បង

ទើបជាកំណប់ទ្រព្យគឺបុណ្យដែលបុគ្គលបានកប់ទុកដោយប្រពៃ នរណាផ្ទាញ់យកក៏មិនបាន ហើយជូនខ្លួនយើងទៅ មិនលះបង់ខ្លួនយើងឡើយ ចោរលួចយកមិនបាន មិនសាធារណ៍ដល់ជនដទៃ កំណប់ទ្រព្យគឺបុណ្យនេះ ឲ្យសម្រេចនូវសេចក្ដីប្រាថ្នាទាំងពួង នរជនប្រាថ្នាយ៉ាងណា ក៏បានយ៉ាងនោះ ហេតុនេះហើយបានជាជនមានប្រាជ្ញាទាំងឡាយ ជាអ្នកស្គាល់នូវពាក្យពេចន៍នៃអ្នកប្រាជ្ញ ជាអ្នកមិនកំណាញ់ រមែងឲ្យនូវទានសព្វៗកាលដើម្បីបុណ្យ សមដូចពុទ្ធភាសិតថា :

"បុរសស្ត្រីណាមានអរិយទ្រព្យទាំងឡាយនេះ គេថាគេហៅបុរសស្ត្រីនោះថា មិនមែនជាអ្នកទុរគតទេ, ជីវិតនៃបុរសស្ត្រីនោះមិនមែនមោឃៈទេ" ។

នរជនមានអរិយទ្រព្យ ទោះជាព្រះរាជាក្ដី គហបតីមហាសាលក្ដី អ្នកទីទ័លក្ដី អ្នកល្ងង់ខ្លៅក្ដី អ្នកប្រាជ្ញក្ដី ជនណាមួយក្ដី ឈ្មោះថា អ្នកមានបុណ្យ ៗ នៅក្នុងលោកនេះ អ្នកមានបុណ្យ តែងបានអានិសង្សគឺមានជនស្រឡាញ់រាប់អាន មានសេចក្ដីក្លៀវក្លា មានកេរ្តិ៍ឈ្មោះ ធ្វើមរណកាលមិនវង្វេង ស្លាប់ទៅកាន់បរលោកបានទៅកាន់សុគតិ ៗ អ្នកមានបុណ្យរមែងរីករាយក្នុងលោកនេះ ដោយការរីករាយចំពោះកម្មដ៏បរិសុទ្ធដែលខ្លួនបានធ្វើហើយ ព្រោះគិតឃើញថា "អាត្មាអញបានធ្វើតែអំពើបុណ្យ ចំណែកបាបអាត្មាអញឥតបានធ្វើសោះ" ។

លុះធ្វើមរណកាលទៅកាន់បរលោកហើយបានស្ថិតនៅក្នុងសុគតិ ក៏រមែងរីកសាយទៀត ។ បុណ្យនេះជាទីពឹងនៃសត្វទាំងឡាយក្នុងលោកខាងមុខ, អាចជួយឲ្យបានសេចក្ដីសុខក្នុងលោកនេះយ៉ាងណា បុណ្យជាកល្យាណ-មិត្រជួយឲ្យបុគ្គលប្រសព្វសេចក្ដីសុខ ក្នុងលោកខាងមុខយ៉ាងនោះដែរ សមដូចពុទ្ធភាសិតក្នុងនិធិកណ្ឌសូត្រថា បុណ្យនេះជាអភិសំខារនិមិត្តឲ្យមានពណ៌ផូរផង់ មានសម្លេងពិរោះ មានទ្រង់ទ្រាយល្អ មានរូបល្អ បានជាធំ មានបរិវារ ទាំងអស់នេះ តែងបានដោយកំណាប់ទ្រព្យគឺបុណ្យ; បានជាព្រះរាជាមានឥស្សរិយយស ជាស្ដេចចក្រពត្រាធិរាជជាទីស្រឡាញ់ បានជាស្ដេចទេវតាក្នុងទិព្វនិកាយ ទាំងអស់នេះតែងបានដោយកំណាប់ទ្រព្យគឺបុណ្យ; បានមនុស្សសម្បត្តិ បានទេវសម្បត្តិ បាននិព្វានសម្បត្តិ ទាំងអស់នេះតែងបានដោយកំណាប់ទ្រព្យគឺបុណ្យ; មានមិត្រ, ស្ទាត់ជំនាញក្នុងវិជ្ជាវិមុត្តិ មានសម្បទា វិមោក្ខ សាវកបារមី បច្ចេកពោធិ ពុទ្ធភូមិ ទាំងអស់នេះ តែងបានដោយកំណាប់ទ្រព្យគឺបុណ្យ ។ បុញ្ញសម្បទានេះ មានប្រយោជន៍ធំក្រៃលែងដោយប្រការដូច្នេះ ។

ភិក្ខុ ប៉ាង-ខាត់

# សង្គហធម៌

(តមកនឹងចប់)

២–អត្ថសំហិតា វាចា សំដីដែលប្រកបដោយប្រយោជន៍ ។

សំដីពីរោះផ្អែមល្ហែម ជាសំដីអាចទាញចិត្តមនុស្សឲ្យមានមេត្រីរាប់រកគ្នាបាន ដូចយ៉ាងមាតាបិតានិយាយសំដីទន់ភ្លន់ហៅរកកូនប្រុសស្រីមានហៅថា "អ្នក, នាង" ជាដើម ជាសំដីគួរជាទីពេញចិត្តនៃកូនប្រុសស្រី ៗ រីឯកូនប្រុសស្រីបេះស្រដីហៅរកមាតាបិតា សន្តានព្រៀងលានទូទៅ ដោយនូវពាក្យពិរោះដឹងគួរដឹងសម មាតាបិតារមែងសប្បាយរីករាយស្រឡាញ់ពេញចិត្តចំពោះកូននោះពន់ពេក ៗ គ្រូអាចារ្យហៅរកសិស្សគណៈដោយពាក្យទន់ភ្លន់ ឯសិស្សគណៈវិញក៏ត្រូវឆ្លើយបរទារួសរាយដោយពាក្យសុភាពរាបសារ ដឹងខ្ពស់ដឹងទាប ៗ នាម៉ឺន មន្ត្រីឬអ្នកធំបេះគួរសមនិយាយប្រស្រ័យនឹងរាស្ត្រប្រជា ដោយពាក្យពិរោះពិសាផ្អែមល្ហែម រមែងបានជាទីស្រឡាញ់រាប់អាននៃប្រជាជនទូទៅ ៗ

ក្នុងលោកនេះ, គេត្រូវការចង់ស្តាប់ចង់ឮតែសំដីពិរោះមានប្រយោជន៍ ៗ គេមិនត្រូវការចង់ស្តាប់ចង់ឮសំដីទ្រគោះបោះបោក, រម៉ាំងរម៉ោក ខ្ទោះខ្វរ ឬសំដីជេរប្រទេចផ្តាសា បន្តុះបង្អាប់គ្នាទេ ៗ ព្រោះហេតុនោះ ពាក្យសំដីទ្រគោះខ្វីខ្វា គំហកគំហើនទាំងនោះ ជាសំដីមិនគួរនិយាយសោះឡើយ ៗ ព្រះពុទ្ធជាបរមគ្រូព្រះអង្គទ្រង់ត្រះតិះដៀលសំដី

អាក្រក់នេះដោយន័យច្រើនប្រការណាស់ ៗ ទ្រង់ត្រាស់ចំពោះឆព្វគ្គិយភិក្ខុថា ភិក្ខវេ ហៃភិក្ខុសង្ឃអ្នកឃើញនូវភ័យក្នុងសំសារទាំងឡាយអើយ ! ធម្មតាសំដីអាក្រក់ សំដីអុជអាលទ្រគោះបោះបោកគំហកគំហើនជាសំដីធ្វើនូវសេចក្តីវិនាសជាអនេកប្រការ កុំថាតែមនុស្ស សូម្បីតែសត្វតិរច្ឆានក៏មិនគាប់ចិត្តនឹងសំដីនេះដែរ ៗ ព្រះបរមគ្រូទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ទ្រង់មានព្រះបន្ទូលចំពោះភិក្ខុទាំងឡាយថា

មនុញ្ញមេវ ភាសេយ្យ　　នាមនុញ្ញំ កុទាចនំ
មនុញ្ញំ ភាសមានស្ស　　គរុំ ភារំ ឧទទ្ធរិ
ធនញ្ច នំ អលោភេសិ　　តេន ចត្តមនោ អហុ ៗ

“ គួរនិយាយតែពាក្យល្អគួរជាទីពេញចិត្ត, មិនគួរនិយាយពាក្យអាក្រក់មិនគួរជាទីពេញចិត្តក្នុងកាលណាមួយឡើយ ៗ គោឈ្មោះនន្ទិវិសាល កាលដែលព្រាហ្មណ៍ជាម្ចាស់ពោលពាក្យពិរោះគួរស្រណោះដល់ត្រចៀក ក៏ខំអូសទាញនូវបន្ទុកយ៉ាងធ្ងន់ ញុំាងព្រាហ្មណ៍ជាម្ចាស់ឲ្យបាននូវទ្រព្យយ៉ាងក្រាស់ក្រែល ហើយជាសត្វសប្បាយចិត្តខ្លួនឯង ព្រោះតែអំពើដែលខ្លួនធ្វើចំពោះព្រាហ្មណ៍ជាម្ចាស់ ” ៗ

ពុទ្ធសាសនិកជនទាំងឡាយ គួរតែនិយាយពាក្យពិរោះពិសាគួរជាទីពេញចិត្ត, កុំគប្បីនិយាយពាក្យអាក្រក់មិនជាទីពេញចិត្តឡើយ ៗ

ម្យ៉ាងទៀត, ជនអ្នកមានចំណេះវិជ្ជា ចេះដឹងជ្រៅជ្រះយ៉ាងណាក៏ដោយ បើនិយាយពាក្យទ្រគោះគំរោះគំរើយ មិនជាទីពេញចិត្តនៃអ្នកស្តាប់ហើយ ក៏រមែងទៅជាឥតមានគេរាប់រក ឬ ចូលចិត្តចង់ស្តាប់ទៅវិញ ។ ឯជនអ្នកខ្សត់ចំណេះសោះទេ តែចេះនិយាយពាក្យសំដីសុភាពរាបសា ដឹងគួរដឹងសម ចេះទុនលំទោនគោរពចាស់ព្រឹទ្ធាចារ្យ នឹងបុគ្គលជារៀមច្បង គង់មានគេរាប់រកគេសង្គ្រោះគេឬជាខ្វះៗ ពុំខាន ។ ការចរចាប្រស្រ័យទាក់ទងរវាងមាតាបិតានឹងបុត្រធីតា គ្រូអាចារ្យនឹងសិស្ស, ស្វាមីនឹងភរិយា, មិត្តសម្លាញ់នឹងមិត្តសម្លាញ់ផងគ្នា, ចៅហ្វាយនាយនឹងអ្នកក្រោមបង្គាប់, អ្នកធំនឹងអ្នកតូចជាដើម គួរតែចរចាសំដីពីរោះគួរជាទីស្រឡាញ់ពេញចិត្តកាន់គ្នាទៅវិញទៅមក អ្នកធំគួរតែចេះស្រឡាញ់រាប់អានអ្នកតូច ដោយការពោលពាក្យគួរជាទីពេញចិត្ត កុំហៅគ្នា អា មឹង មី ហង, គួរហៅគ្នាឲ្យសមរម្យតាមឋានៈថា "បង, ប្អូន" (តាមបងតាមប្អូន) ឬហៅថា "នាយ, អ្នក, នាង, ពូ, មីង, ធំ, លោកយាយ, លោកតា (តាមវ័យក្មេងចាស់) វិញ ទើបសមស័ក្តិជាមនុស្សសុភាពជាអ្នកស្លូតត្រង់ ដើម្បីប្រមូលប្រជាជនគ្រប់ថ្នាក់គ្រប់ជាន់គ្រប់ផ្នែកឲ្យមូលមិត្តរួមចិត្តគំនិតជាមួយគ្នា ព្រោះថាសំដីពិរោះពីសាទន់ភ្លន់ផ្អែមល្ហែមនេះជាគុណជាតិនាំឲ្យបានសម្រេចប្រយោជន៍ច្រើនជាអនេក ។

ចំណែកខាងអត្ថសញ្ហិតា វាចា ដែលប្រែថា សំដីប្រកបដោយប្រយោជន៍នោះ គឺបានខាងការរៀន បុគ្គលមិននិយាយសំដីឡេះឡោះឥតបានការ ឥតបានប្រយោជន៍ដល់ខ្លួននិងអ្នកស្ដាប់ ជាសំដីរោយរាយផ្ដេសផ្ដាសឥតគោលចារឹក សំដីតាមតែនឹកឃើញ ជាសំដីធ្វើអ្នកនិយាយនិងអ្នកស្ដាប់ឲ្យរាយមាយចិត្តមិនស្ងប់រម្ងាប់ ហើយនិយាយតែសំដីណាដែលមានប្រយោជន៍ដែលនាំខ្លួនអ្នកនិយាយនិងអ្នកស្ដាប់ឲ្យបានសម្រេចប្រយោជន៍គឺសេចក្ដីសុខ-ចំរើន ព្រោះថាបើអ្នកស្ដាប់នោះធ្វើតាមឬប្រតិបត្តិតាមសំដីខ្លួនហើយ នឹងបានផលដល់ខ្លួនជាប្រាកដ ។ ម្យ៉ាងទៀត សំដីប្រកបដោយប្រយោជន៍ សុទ្ធតែជាសំដីសំដែងសេចក្ដីតាមពិតតាមមែន ជាសំដីមានខ្លឹមសារមិនចេះសាបសូន្យឬប្រែប្រួលវិនាសទៅដោយហេតុណាមួយឡើយ ជាសំដីមានតម្លៃថ្លៃថ្លាលើសលែងវត្ថុៗ ទាំងអស់ ជាសំដីមានឱជារសឆ្ងាញ់ពិសាដល់ចិត្តជានិច្ច ហើយថែមទាំងឋិតថេរចិរកាលជាងវត្ថុដែលរឹងខ្ជាប់ខ្ជួនមានដែកថ្មជាដើម ដូចមានភាសិតសំដែងថា "របស់ដែលមានរសផ្អែម ហើយតាំងនៅជាស្ថាពរយូរអង្វែងទៅបាន គឺពាក្យសំដីមានប្រយោជន៍ (អត្ថសញ្ហិតា វាចា)" ។

ពុទ្ធសាសនិកជនទាំងឡាយ គួរនិយាយតែពាក្យពីរោះពិសាពាក្យមានប្រយោជន៍ដល់ខ្លួន និងអ្នកស្ដាប់តែម្យ៉ាង កុំនិយាយពាក្យទ្រគោះទ្រោះខ្វះឥតប្រយោជន៍សោះឡើយ ។ ព្រោះថាពាក្យសំដីមានប្រយោជន៍

នេះឯង រមែងជាបច្ច័យនាំមកនូវសេចក្ដីសុខ-ចំរើនក្នុងលោកទាំងពីរ ។ កុំថាតែនិយាយខ្លួនឯង សូម្បីតែស្ដាប់អ្នកដទៃនិយាយ ក៏អាចសម្រេចប្រយោជន៍ដល់បុគ្គលអ្នកស្ដាប់ដែរ មិនតែប៉ុណ្ណោះ បើបុគ្គលអ្នកស្ដាប់នោះយកចិត្តទុកដាក់ជឿតាមប្រតិបត្តិតាមហើយ ក៏នឹងអាចកែខ្លួនឲ្យជាអ្នកខ្ពង់ខ្ពស់ចំរើនយសសក្តិ មានចិត្តស្លូតត្រង់សុភាពរៀបរយទៅបាន ដូចយ៉ាង រឿងព្រះបាទធម្មាសោករាជ ៙

ព្រះបាទធម្មាសោករាជ បរមក្សត្រប្រទេសឥណ្ឌាភាគកណ្ដាល ក្នុងបុរាណសម័យ មានព្រះរាជហឫទ័យធុរជេរក្រេវក្រោធកាចខ្លាំងណាស់ តែទ្រង់ខ្ញាល់នឹងអ្នកណា ក៏ត្រាស់ព្រះរាជបញ្ជាឲ្យប្រហារពិឃាតអ្នកនោះ ១ រំពេច សូម្បីព្រះអនុជរបស់ព្រះអង្គក៏ទ្រង់ប្រហារពិឃាតដោយព្រះហស្ដព្រះអង្គឯងអស់ ៩៩ ព្រះអង្គ តែតមកខាងក្រោយ ទ្រង់បានព្រះសណ្ដាប់ពុទ្ធភាសិតដែលនិគ្រោធសាមណេរ ជាព្រះភាគិនេយ្យរបស់ព្រះអង្គសំដែងថ្វាយ ទ្រង់ក៏ជ្រះថ្លារីករាយចំពោះភាសិតដែលជាពាក្យមានប្រយោជន៍នោះ បានលះបង់អំពើអាក្រក់ដែលទ្រង់ធ្លាប់ប្រព្រឹត្តមក ប្រែជាមានព្រះហឫទ័យសុភាព ស្លូតត្រង់ទំនុកបំរុងព្រះពុទ្ធសាសនា មានព្រះរាជសទ្ធាជ្រះថ្លាធ្វើបុណ្យឲ្យទាន មានសាងវិហារកុដិសាលានឹងចេតិយដ្ឋានតូច-ធំជាដើមជាច្រើន ៗ ចំណេរតមក ទ្រង់បានសណ្ដាប់ធម្មទេសនា នៃព្រះមោគ្គលីបុត្តតិស្សមហាថេរទៀត, ទ្រង់ក៏រឹងរឹតតែ

ដ្រះថ្វាជាកិយោភាគ  បានកសាងព្រះវិហារនឹងចេតិយដ្ឋាន ៨ ម៉ឺន ៤ ពាន់ បូជាព្រះធម្មក្ខន្ធ គ្រប់នគរក្នុងសកលជម្ពូទ្វីប នឹងទ្រង់បំពេញព្រះរាជកុសលដទៃទៀតជាច្រើន មានជួយទំនុកបំរុងក្នុងការធ្វើតតិយសង្គាយនា ក្នុងសតវត្សរ៍ទី ៣ នៃពុទ្ធសករាជជាដើម ដរាបដល់ល្បីព្រះបរមនាមរន្ទឺខ្ទរខ្ទាយសាយសុះទៅក្នុងលោកថា ព្រះបាទធម្មាសោករាជ ។

ការពោលពាក្យពីរោះគួរឲ្យចង់ឮ ចង់ស្តាប់ ព្រមទាំងមានប្រយោជន៍ដូចបានអធិប្បាយមកប៉ុណ្ណេះចាត់ជាសង្គហធម៌ទី ២ ជាធម៌សម្រាប់សង្គ្រោះស្រោចស្រង់ប្រជាជនគ្រប់ប្រភេទឲ្យមានមេត្រីមូលមិត្រគ្នាតអង្វែងទៅ ។

៣ — អត្ថចរិយា .— ការប្រព្រឹត្តឲ្យកើតផលប្រយោជន៍ ឬឲ្យកើតសេចក្តីចំរើនដល់គ្នា ហៅថា អត្ថចរិយា ។ អត្ថចរិយានេះ ជាគុណជាតិដ៏សំខាន់បំផុត អាចសង្គ្រោះគ្នាឲ្យបានសេចក្តីសុខចំរើនទៅបាន ។ ការសង្គ្រោះគ្នាដោយឲ្យប្រយោជន៍ ឬសេចក្តីចំរើនដល់គ្នានឹងគ្នានេះ បានដល់ការមិនមើលបំណាំគ្នា ។

មែនពិត , ការឲ្យ នឹងការនិយាយពាក្យពីរោះពិសាគួរជាទីពេញចិត្ត ជាហេតុនាំឲ្យមានមេត្រីមូលមិត្រគ្នាយ៉ាងស្អិទ្ធគួរឲ្យទុកចិត្តថាបានសេចក្តីសុខ-ចំរើនពិតមែនហើយ ក៏ប៉ុន្តែបើចេះតែមើលបំណាំគ្នា មិនស្វែងរកប្រយោជន៍ឲ្យដល់គ្នានឹងគ្នា គឺថាបើគ្រាន់តែឲ្យ នឹងនិយាយ

ពាក្យពិពេះប៉ុណ្ណោះ មិនប្រព្រឹត្តអំពើជាប្រយោជន៍ដល់គ្នានឹងគ្នាថែមទៀតផងទេ នោះសេចក្តីសុខស្រួលនឹងមេត្រីភាពមានទាំងប៉ុន្មាននឹងវិនាសសាបសូន្យទៅវិញដោយឆាប់រហ័ស ព្រោះហេតុនោះ ទើបយើងត្រូវប្រព្រឹត្តឲ្យកើតផលប្រយោជន៍នឹងសេចក្តីចំរើនដល់គ្នាថែមទៀត ។ រីឯការប្រព្រឹត្តិដើម្បីប្រយោជន៍នឹងសេចក្តីចំរើនដល់គ្នានឹងគ្នានោះ ត្រូវប្រព្រឹត្តតាមស្ថានដូចអធិប្បាយតទៅនេះ :

ស្ថានទី ១

## មាតាបិតា នឹងបុត្រធីតា

មាតានឹងបិតាត្រូវប្រព្រឹត្តដើម្បីប្រយោជន៍ដល់បុត្រធីតា ដោយការទំនុកបំរុងផងផ្តើមឲ្យកូនសិក្សារៀនសិល្បសាស្ត្រមន្តវិជ្ជាការ ចំណេះទាំងផ្លូវលោកទាំងផ្លូវធម៌ តាំងពីកាលដែលកូននៅក្នុងបឋមវ័យ កំពុងមាននិស្ស័យទន់ខ្ចី អាចនឹងបង្ហោនចិត្តផ្ចិតយកវិជ្ជាចំបានដោយងាយ កុំបណ្តោយឲ្យកូនប្រុសស្រីចំរើនវ័យធំដែងក ខ្ជិលចំណេះតតបេះដឹងអ្វីសោះឡើយ ព្រោះថាមានប្រយោជន៍អ្វី ដោយកូនដែលល្ងង់ខ្លៅនោះ? អ្នកប្រាជ្ញពីបុរាណលោកពោលទុកថា:

កោ’ត្ថៈ បុត្តេន ជាតេន យោ ន វិទ្វា ន ធម្មិកៈ
កាណេន ចក្ខុនា កឹ វា ចក្ខុះ បីឡេវ កេវលំ ។

"មានប្រយោជន៍អ្វី បើកូនកើតមកល្ងង់ខ្លៅ មិនប្រកបដោយធម៌? ដូចភ្នែកដែលឈឺ តើមានប្រយោជន៍អ្វី? បានត្រាន់តែឈឺចាក់ដោតនាំឲ្យរំខានប៉ុណ្ណោះ" ។

កោ ធន្យោ ពហុភិះ បុត្រៃះ កុឝូលាបូរណាឍកៃះ
វរមេកះ កុលាលម្ពី យត្រ វិឝ្រូយតេ បិតា ។

"គួរនឹងរាប់មាតាបិតាដែលបង្កើតកូនបានច្រើនថាគាប់ប្រសើរឬទេ បើកូនទាំងឡាយនោះ ប្រៀបដូចជានាឡិទេក្នុងជង្រុក? កូនតែម្នាក់ជាទីពឹងផ្អែកទំនុកបំរុងត្រកូលល្អជាជាង; កេរ្តិ៍ឈ្មោះបិតានឹងល្បីរន្ទឺខ្ចរខ្ចាយទៅសព្វទិសានុទិស" ។

មាតាបិតាត្រូវឧបត្ថម្ភកូនប្រុសស្រី ឲ្យចេះរករបរចិញ្ចឹមជីវិតដោយជួយឧបត្ថម្ភឲ្យទ្រព្យសម្បត្តិគោក្របីស្រែចំការជាដើមទុនហើយត្រូវរៀបចំទុកដាក់កូនប្រុសស្រីឲ្យមានស្វាមីភរិយា តាមសមគួរដល់គោត្រត្រកូលជាដើម ។ ឯបុត្រធីតាវិញ ត្រូវបំពេញករណីយកិច្ចរបស់ខ្លួន ចំពោះមាតាបិតា ដោយការចិញ្ចឹមបីបាច់ថែទាំរក្សាផ្គត់ផ្គង់បំរើបាយទឹកចំណីសំពត់ស្លៀកពាក់ ទីស្នាក់អាស្រ័យ, ជួយធ្វើកិច្ចការរវល់របស់មាតាបិតា ណែនាំមាតាបិតាឲ្យសមាទាន រក្សាសីល ដំកល់ក្នុងសីលធម៌ជាដើម ។

ស្ពានទី ២

## គ្រូអាចារ្យ និងសិស្សគណ

គ្រូអាចារ្យត្រូវប្រព្រឹត្តដើម្បីប្រយោជន៍ដល់ពួកសិស្ស ដោយការខំបង្ហាត់បង្រៀនចំណេះវិជ្ជាមានបង្ហាត់ឲ្យចេះអក្សរសាស្ត្រជាតិ ព្រមទាំងចតុក្កិធលេខជាដើមឲ្យបានចេះប្រាកដដោយមិនលាក់ទុក គឺថាបើខ្លួនចេះប៉ុន្មាន ក៏បង្ហាត់បង្រៀនសិស្សឲ្យចេះប៉ុណ្ណោះ, លុះដល់ពេលដែលសិស្សចេញពីសំណាក់របស់ខ្លួនទៅកាន់ទីដទៃ មានទៅសិក្សាបន្តចំណេះវិជ្ជាតទៅទៀតជាដើមនោះ គ្រូអាចារ្យមិនត្រូវខារខាំងរាំងរហាមឃាត់សិស្សឡើយ ត្រូវតែជួយបណ្ដុះបណ្ដាលសិស្សឲ្យខំរៀនសូត្រតាមចំណង់ ហើយត្រូវជួយទំនុកបំរុងសិស្សដោយសំលៀកបំពាក់ប្រាក់កាស ឬដោយដំបូន្មានពាក្យប្រៀនប្រដៅក្រើនរំឭកដាស់តឿនតាមសមគួរ ដល់កាលសម័យ ដើម្បីឲ្យសិស្សរីករាយសប្បាយចិត្តនឹងខ្លួនព្រមទាំងរៀនសូត្រជាប់ជានិច្ច ។ ចំណែកខាងសិស្សត្រូវមាននាទីខាងប្រតិបត្តិគ្រូអាចារ្យដោយការផ្គត់ផ្គង់បំរើ និងជឿស្ដាប់ពាក្យឱវាទដែលលោកទូន្មានប្រៀនប្រដៅដោយល្អជាដើម ។

ស្ពានទី ៣

## ស្វាមី និង ភរិយា

ស្វាមីត្រូវសង្គ្រោះភរិយា ដោយការស្រឡាញ់រាប់អានដោយស្មោះ

ត្រង់, មិនប្រមាថមើលងាយប្រពន្ធដូចជាខ្ញុំកំដរបាវព្រាវ, មិនប្រព្រឹត្តក្បត់ចិត្តប្រពន្ធ, ប្រគល់អំណាចក្នុងផ្ទះឲ្យប្រពន្ធជាប់មុខ នឹងស្វែងរកគ្រឿងអលង្ការឲ្យប្រពន្ធ ដើម្បីឲ្យប្រពន្ធមានមេត្រីស្មោះត្រង់ជានិច្ច ៗ រីឯប្រពន្ធក៏ត្រូវប្រតិបត្តិដើម្បីប្រយោជន៍ដល់ស្វាមីឲ្យត្រឹមត្រូវវិញដែរ គឺត្រូវចេះរៀបចំបុកពាកិរិយាមារយាទឲ្យស្រគត់ស្រគំសមរម្យ, ចេះនិយាយស្តីពីរោះផ្អែមល្ហែមមិនទ្រគោះបោះបោក, ចេះរៀបចំទុកដាក់ទ្រព្យសម្បត្តិមិនចោលពាក់ពាយ មិនបណ្តាយឲ្យវិនាសអន្តរាយឲ្យខូចអសារឥតការដោយហេតុណាមួយ, ឧស្សាហ៍ធ្វើការងារគ្រប់ជំពូកមិនបំអៀកខ្ជិលច្រ-អូស ស្រឡាញ់រាប់អានញាតិសន្តានព្រៀងលានខាងប្តីនិងខាងខ្លួនទោះបីជិតឆ្ងាយ ចេះធ្វើម្ហូបចំណីស្លដណ្តាំព្រមទាំងកិច្ចការគ្រប់ចំពូកដែលជាមុខងាររបស់ខ្លួនមិនឲ្យខុសឆ្គង, សូម្បីប្តីខ្សត់ក្រយ៉ាងណា ក៏មិនប្រមាថមើលងាយ បើប្តីមានទុក្ខក៏ស៊ូទ្រាំជួយដោះទុក្ខធុរៈគ្នាតាមសមត្ថភាព ៗ

មែនពិត, ប្តីនិងប្រពន្ធទាំងពីរនាក់ ត្រូវតែអាស្រ័យគ្នាទៅវិញទៅមក នឹងបែកចិត្តគំនិតចេញពីគ្នាពុំបាន ដូចមានពាក្យបុរាណថា "ប្តីទុកជាជើងមុខ ប្រពន្ធទុកជាជើងក្រោយ" អ្នកទាំងពីរត្រូវកាន់កាប់នាទីរបស់ខ្លួនឲ្យម៉ត់ចត់ ទើបអាចនឹងធ្វើគ្រួសារវង្សត្រកូលឲ្យបានសេចក្តីសុខ-ចំរើនថ្កុំថ្កើងរុងរឿងតទៅ ៗ

### ស្ថានទី ៤

# មិត្រសម្លាញ់ នឹងមិត្រសម្លាញ់

ជនជាមិត្រសម្លាញ់នៃគ្នានឹងគ្នា ត្រូវប្រព្រឹត្តប្រយោជន៍ចំពោះគ្នានឹងគ្នាដូច្នេះគឺ បើឃើញមិត្រសម្លាញ់ធ្វេសប្រហែសភ្លាំងភ្លាត់ដែលទៅធ្វើអំពើពុំសមគួរផ្សេងៗ មិនមើលបំណាំ ឬលះបង់ចោលមិត្រ ជួយណែនាំមិត្រឲ្យប្រព្រឹត្តល្អបានសេចក្ដីសុខស្រួល; បើមានភ័យកិតកើតឡើងដល់មិត្រ មិនលះបង់ចោល ជួយប្រាប់ពន្យល់ពុំកស្មារតីឲ្យមិត្រមានសេចក្ដីកក់ក្ដៅ ហើយឈឺឆ្អាលការពារមិត្រ ត្រាតែស្បើយភ័យនោះ ដូចបុរាណភាសិតពោលទុកថា :

អាបត្សុ មិត្រំ ជានីយា– ទ្យុទ្ធេ ឝូរម្ឫណេ ឝុចិំ
ភាយ៌ាំ ក្សីណេឞុ វិត្តេឞុ វ្យសនេឞុ ច ពាន្ធវាន៑ ។

“គេដឹងចិត្តមិត្រក្នុងគ្រាក្រ, ដឹងចិត្តទាហានក្លាហានក្នុងសង្គ្រាម, ដឹងចិត្តស្មោះត្រង់ក្នុងកាលសងបំណុលគេ, ដឹងចិត្តភរិយាក្នុងពេលខ្សត់ទ្រព្យ ហើយដឹងចិត្តផៅពង្សក្នុងគ្រាវិនាសអន្តរាយ” ។

ឧត្សវេ វ្យសនេ ចៃវ ទុព្ភិក្សេ រាស្ត្រវិប្លវេ
រាជទ្វារេ ស្មសានេ ច យស្តិស្ឋតិ ស ពាន្ធវៈ ។

"អ្នកណាមិនលះបង់មិត្តក្នុងគ្រាមានទុក្ខភ័យ ក្នុងគ្រាអន្តរាយ ក្នុងគ្រាទុរ្ភិក្ស ក្នុងគ្រាកស្រ្តចលាចល ក្នុងទ្វារព្រះរាជា នឹងព្រៃស្មសាន អ្នកនោះលោកទុកថាជាផៅពង្សពិតប្រាកដ" ។

ម្យ៉ាងទៀត, កាលបើកិច្ចការដែលត្រូវធ្វើកើតឡើងដល់មិត្តត្រូវជួយធ្វើកិច្ចការនោះ, ត្រូវហាមប្រាមមិត្តកុំឲ្យធ្វើអំពើអាក្រក់ផ្សេង ៗ, ណែនាំមិត្តឲ្យដំកល់ខ្លួនក្នុងកុសលធម៌មានត្រៃសរណគមន៍ សីល ៥ កម្មបថ ១០ ជាដើម; ជាអ្នករួមសុខរួមទុក្ខជាមួយមិត្ត ប្រាប់ពន្យល់ផលប្រយោជន៍ដល់មិត្ត មានសេចក្ដីអនុគ្រោះចង់ឲ្យមិត្តបានល្អលាស់ចំរើនដោយចំណេះវិជ្ជា ទ្រព្យសម្បត្តិ កេរ្តិ៍ឈ្មោះ យសសក្តិចំរើនរុងរឿង ។

កាលបើមិត្តសម្លាញ់នឹងមិត្តសម្លាញ់ បានប្រព្រឹត្តតាមស្ថានដើម្បីជាប្រយោជន៍ដល់គ្នាទៅវិញទៅមកយ៉ាងនេះហើយ ឈ្មោះថាបានប្រមូលសេចក្ដីសុខក្សេមក្សាន្ត នឹងសេចក្ដីចំរើនគ្រប់យ៉ាងមកឲ្យខ្លួនជាប្រាកដ ។ សមដូចព្រះពុទ្ធដីកាក្នុងសិង្គាលោវាទសូត្រថា :

ឧបការោ ច យោ មិត្តោ សុខទុក្ខោ ច យោ សខា
អត្ថក្ខាយី ច យោ មិត្តោ យោ ច មិត្តានុកម្បកោ
ឯតេបិ មិត្តេ ចត្តារោ ឥតិ វិញ្ញាយ បណ្ឌិតោ
សក្កច្ចំ បយិរុបាសេយ្យ មាតា បុត្តំ ឱរសំ ។

“មិត្តណាជាអ្នកមានឧបការៈ ជាអ្នករួមសុខរួមទុក្ខជាមួយគ្នា ជាអ្នកណែនាំប្រាប់ប្រយោជន៍ នឹងជាអ្នកមានសេចក្តីអនុគ្រោះ, អ្នកមានប្រាជ្ញា បើដឹងថាមិត្តទាំង ៤ ពួកនុះជាមិត្តពិតប្រាកដហើយ គប្បីចូលទៅអង្គុយជិតស្និទ្ធស្នាលនឹងមិត្តនោះ ដូចជាម្តាយនឹងកូនទៅចុះ” ។

សូម្បីជនជាញាតិសន្តានសាច់សាលោហិតទាំងឆ្ងាយទាំងជិតក្តី ជាបើបូរបាច់ឲ្យសព្វគ្រប់ទៅ សូម្បីជនរួមជាតិជាមួយគ្នាក៏ត្រូវតែជួយផ្តល់ប្រយោជន៍ឲ្យតាមសមគួរដូចជាមិត្តសម្លាញ់ទាំងពួងផងដែរ ដើម្បីឲ្យមានមេត្រីចិត្តរាប់រកគ្នាយ៉ាងជិតស្និទ្ធ ។

ឋានទី ៥

## ទាសៈកម្មករ ខ្ញុំកំដរបាវព្រាវ, អ្នកធ្វើការឈ្នួល អ្នកធ្វើការក្រោមបង្គាប់, អ្នកតូចនឹងចៅហ្វាយ

ទាសៈកម្មករជាដើម ត្រូវយកចិត្តទុកដាក់បំពេញបំបានចៅហ្វាយនាយដោយៈ

ក) ធ្វើការមុនចៅហ្វាយជានិច្ច ។

ខ) ឈប់ធ្វើការក្រោយចៅហ្វាយនាយជាដរាប ។

គ) មិនលួចមិនលាក់មិនបំបាត់ទ្រព្យរបស់ចៅហ្វាយនាយ ។

ឃ) ធ្វើការដែលចៅហ្វាយដាក់ឲ្យធ្វើ ដោយយកចិត្តទុកដាក់មិនខ្ជិលច្រអូស ;

ង) សរសើរចៅហ្វាយក្នុងពេល ឬ ក្នុងទីដ៏គួរ ៗ

ចំណែកខាងចៅហ្វាយគ្រប់ផ្នែកគ្រប់ជាន់ត្រូវសង្គ្រោះទាសៈកម្មករ អ្នកធ្វើការក្រោមបង្គាប់ ដោយស្ថានដូចតទៅនេះ :

១ – ត្រូវដាក់ការងារឲ្យធ្វើឲ្យសមតាមកំឡាំងនឹងសមត្ថភាព ៗ

២ – ត្រូវចាត់ចែងថ្លៃឈ្នួល ឬបៀវត្ស ប្រាក់បំណាច់រង្វាន់ជាដើម តាមសមគួរដល់កិច្ចការនោះ ៗ កុំឲ្យលើសខ្វះ ឬ តិចច្រើនជាងគ្នាហួសប្រមាណ ;

៣ – ជួយថែរក្សាការពារឲ្យបានសេចក្ដីសុខ ៗ

៤ – ចែករំលែកវត្ថុមានរសឆ្ងាញ់ ៗ

៥ – បើកឲ្យឈប់ធ្វើការក្នុងឱកាសមានបុណ្យទានធំ ៗ មានថ្ងៃនក្ខត្តឫក្ស នឹងថ្ងៃចូលឆ្នាំជាដើម ៗ

ម្យ៉ាងទៀត បុគ្គលជានាយចៅហ្វាយ ឬ ជានាយកត្រួតត្រាលើគេ ត្រូវជាអ្នកប្រកបដោយគុណសម្បត្តិ ៦ យ៉ាងគឺ :

១ – ខមា មានសេចក្ដីអត់ធន់ ចេះទុនចេះអត់ចំពោះកិច្ចការ នឹងចំពោះអ្នកក្រោមបង្គាប់ ;

២ – ជាគរិយ មានសេចក្ដីភ្ញាក់រឭក គឺជាអ្នកវាងវៃក្នុងកិច្ចការសព្វយ៉ាង ;

៣ – ឧដ្ឋាន មានសេចក្ដីប្រឹងប្រែង ខ្នះខ្នែងធ្វើការងារមិនខ្ជិលច្រអូស មិនដំអក់ទំនេរ ;

៤— សំវិភាគ មានការចែករំលែកផលប្រយោជន៍ឲ្យអ្នកក្រោមបង្គាប់ជាប្រក្រតី ;

៥— ទយា មានសេចក្តីអាណិតអាសូរអ្នកធ្វើការក្រោមបង្គាប់ ។

៦— តិក្ខា មានការពិនិត្យត្រួតត្រាមើលជាប្រក្រតី ឲ្យដឹងថាអ្នកធ្វើការក្រោមបង្គាប់របស់ខ្លួន បានធ្វើការនេះ ឬការនោះហើយឬនៅ បានចូលធ្វើការឬចេញពីធ្វើការត្រឹមត្រូវតាមកាលកំណត់ ដែរឬទេអ្នកធ្វើការនោះ ឧស្សាហ៍ឬខ្ជិលច្រអូសជាដើម ។

កាលបើទាសៈកម្មករនឹងចៅហ្វាយនាយ បានប្រព្រឹត្តតាមស្ថានដែលជាកាតព្វកិច្ចរបស់ខ្លួនហើយ ឈ្មោះថាបាននាំនូវសេចក្តីសុខ-ចំរើនគ្រប់ប្រការ មកឲ្យខ្លួនជាប្រាកដ ព្រោះទាសៈកម្មករនឹងចៅហ្វាយនាយនោះ បានមានសេចក្តីទំនុកបំរុងបំពេញបំបានគ្នា ទៅវិញទៅមកជាហេតុនៃមេត្រីជិតស្និទ្ធ ។

ស្ថានទី ៦

## បព្វជិត និងគ្រហស្ថ

បព្វជិតជាអ្នកមានសីលធម៌ល្អ ត្រូវអនុគ្រោះគ្រហស្ថដោយស្ថានដែលមានកម្រិតទុកក្នុងច្បាប់ គឺត្រូវហាមប្រាមកុំឲ្យប្រព្រឹត្តធ្វើអំពើអា-ក្រក់ផ្សេងៗ មានកាប់សម្លាប់លួចប្លន់បំបាត់ប្រវ័ញ្ចន៍ជាដើម ឲ្យធ្វើតែអំពើ

ដែលមិនមានទោស មានរក្សាសីល ៥ កម្មបថ ១០ នឹងឲ្យទានជាដើម ហើយត្រូវប្រាប់ពន្យល់ធម៌ដែលមិនធ្លាប់បានស្ដាប់ឲ្យយល់ចូលចិត្តច្បាស់លាស់ កុំឲ្យមានសេចក្ដីសង្ស័យក្នុងធម៌នោះៗ តទៅទៀត ។ ចំណែកខាងគ្រហស្ថវិញ ត្រូវប្រតិបត្តិផ្គត់ផ្គង់បព្វជិតឲ្យល្អ ដោយកាយកម្មវចីកម្ម នឹងមនោកម្មប្រកបដោយមេត្តា ដោយការឲ្យខាទនីយភោជនីយាហារដល់បព្វជិតរឿយៗជាដើម ។

ម្យ៉ាងទៀត កល្យាណជនអ្នកមានសីលធម៌ ជួយណែនាំប្រាប់ពន្យល់ជនអ្នកឥតមានសទ្ធាឲ្យមានសទ្ធាជ្រះថ្លា ជនអ្នកឥតមានសីលឲ្យមានសីល អ្នកមានសេចក្ដីកំណាញ់ ឲ្យមានការបរិច្ចាគទេយ្យវត្ថុធ្វើបុណ្យឲ្យទាន អ្នកឥតប្រាជ្ញាឲ្យមានប្រាជ្ញា ។ យ៉ាងនេះហៅថាប្រព្រឹត្តប្រយោជន៍ដល់គ្នានឹងគ្នា ។

កាលបើមាតាបិតានឹងបុត្រធីតា, គ្រូអាចារ្យនឹងសិស្ស, ស្វាមីនឹងភរិយា, មិត្រសម្លាញ់នឹងមិត្រសម្លាញ់ផងគ្នា, នាយចៅហ្វាយនឹងខ្ញុំកំដរបាវព្រាវ, បព្វជិតនឹងគ្រហស្ថ បានប្រព្រឹត្តអំពើជាប្រយោជន៍ចំពោះគ្នានឹងគ្នាយ៉ាងនេះហើយ ឈ្មោះថាបានបិទបាំងភ័យអន្តរាយទាំងពួងមិនឲ្យកើតឡើងបាន ឈ្មោះថាញាំងសេចក្ដីសុខ-ចំរើនឲ្យកើតឡើងដល់ខ្លួនជាប្រាកដ ។ អត្ថចរិយា ការប្រព្រឹត្តឲ្យកើតផលប្រយោជន៍ដល់គ្នាដូចបានពណ៌នាមកនេះ ចាត់ជាសង្គហធម៌ទី៣ ជាធម៌សម្រាប់សង្គ្រោះប្រជាជនប្រុសស្រីឲ្យមានមេត្រីមូលមិត្រគ្នាជាអង្វែងតទៅ ។

៤ — សមានត្តតា.— ភាពជាអ្នកតាំងខ្លួនស្មើៗ ឬការតាំងខ្លួនកណ្ដាលៗ ហៅថា សមានត្តតា ។ ធម៌នេះបានដល់ការចេះរៀបចំខ្លួនឲ្យសមរមតាមអត្តភាពជាអ្នកស្គាល់ចាស់ស្គាល់ក្មេងស្គាល់ធំ-តូច មិនប្រកាន់ខ្លួន មិនមើលងាយគេជាអ្នកសុភាពរាបសាល្អត្រឹមត្រូវមិនខ្គងដល់ក្នុងលោក ឬ បើពោលតាមសេចក្ដីម្យ៉ាងទៀតថា ភាពជាអ្នកចេះគួរសមទឹងគ្នាទៅវិញទៅមកតាមសមគួរដល់ឋានៈ ។

មែនពិត, សេចក្ដីគួរសមស្គាល់ចាស់ទុំធំតូចជាដើមនេះជាគ្រឿងដ៏ឧត្តមរបស់ជនប្រុសស្រីក្នុងលោក ។ ព្រោះថា ក្នុងលោកនេះ បើមានតែការឲ្យទាន, ការនិយាយពាក្យពិរោះគួរជាទីស្រឡាញ់, ការណែនាំប្រាប់ប្រយោជន៍ដល់គ្នានឹងគ្នាតែប៉ុណ្ណោះ មិនមានសេចក្ដីគួរសមនឹងគ្នាផងទេ នោះសេចក្ដីរាប់អានក៏នឹងសាបសូន្យទៅវិញដោយរហ័សពុំខាន ព្រោះហេតុនោះ សាធុជនត្រូវអប់រំការប្រព្រឹត្តិស្មើ ឬសេចក្ដីគួរសមនឹងគ្នាទៅវិញទៅមកថែមទៀត ។

មនុស្សយើង ច្រើនតែមិនចេះរៀបចំខ្លួនប្រមាណឲ្យសមតាមអត្តភាព គឺច្រើនតែប្រកាន់មានះក្អេងក្អាង មើលងាយគេធ្វើឫកពាក្រអឺតក្រអោង ព្រហើនកោងកាច ព្រោះអាងអំណាច អាងយសសក្ដិ និងអាងទ្រព្យសម្បត្តិជាដើម ។ ការដែលប្រកាន់មានះក្អេងក្អាងមើលងាយគេនេះឯង

រមែងបានផលទៅជាលែងស្រឡាញ់រាប់អានគ្នា នាំឲ្យសាបសូន្យសេចក្តីរាប់អានគ្នាទៅវិញទៅមក ជាហេតុនាំឲ្យវិនាសក្នុងលោក សមដូចព្រះពុទ្ធដីកាក្នុងបរាភវសូត្រថា :

ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ
សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។

“ជនដែលប្រកាន់ជាតិ ប្រកាន់ទ្រព្យ ប្រកាន់ត្រកូល ហើយមើលងាយញាតិសន្តានរបស់ខ្លួន ហេតុនោះ ជាប្រធានរបស់បុគ្គលអ្នកមានសេចក្តីវិនាស” ។ ដូច្នេះ, ពុទ្ធសាសនិកជនទាំងឡាយ គួរតែជាអ្នកតាំងខ្លួនស្មើៗ ចំពោះបុគ្គលនោះៗ តាមសមគួរ ទើបសេចក្តីស្រឡាញ់រាប់អានមានកម្លាំងអាចតាំងនៅជាស្ថាពរតទៅបាន ។

ព្រះបាឡាត់ពោធិភម ជា-ទន់

---

# កែតម្រូវក្នុងសៀវភៅលេខ ៦-៧

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| មជ្ឈិមយាម | បច្ឆិមយាម | ២១០ | ១៥ |
| ព ស. ១១៣ | ១០១៣ | ២១៩ | ២ |
| ព. ស. ១១៥ | ១១៥៣ | ២២១ | ៥ |

## អក្សរសាស្ត្រជាពន្លឺជាតិ ជាគោលបវរកជាតិ
## អក្សរសាស្ត្ររលត់ ជាតិរលត់ ។

### ព្រះរាជប្រវត្តិ
### ព្រះបាទសម្ដេចព្រះស្រីធម្មរាជា ព្រះរាជសំភារ
(គ.ស. ១៦០០— ១៦៣០)

ព្រះបាទសម្ដេចព្រះស្រីធម្មរាជា ព្រះរាជសំភារ ជាព្រះរាជបុត្រព្រះបាទសម្ដេចព្រះជ័យជេដ្ឋា (ទ្រង់ប្រសូតក្នុង គ.ស. ១៦០០), កាលនៅជាព្រះរាជកុមារទ្រង់ព្រះនាមចៅពញា (តូ) ។ ព្រះបរមរាជបិតាទ្រង់ព្រះគុនាំង៉ានទ់នឹងព្រះនាងបុប្ផាវតី ជាព្រះរាជកនិដ្ឋា ចៅពញា (តូ) ព្រះជន្ម ២១ ឆ្នាំ បេញទ្រង់ព្រះផ្នួស ។

ព្រះបាទសម្ដេចព្រះជ័យជេដ្ឋា ជាព្រះបរមរាជបិតា ទ្រង់ព្រះសុវណ្ណ-គតទៅ សម្ដេចព្រះឧទ័យរាជា ព្រះរាជអណុជក៏បានទទួលរាជការផែនដីក្រុងកម្ពុជា (បណ្ដោះអាសន្នសិន) ព្រោះចៅពញា (តូ) មានសេចក្ដីទាក់ទាមនឹងកិច្ចដែលទ្រង់នៅជាភិក្ខុ ។ ក្នុងរវាងចៅពញា (តូ) ទ្រង់ព្រះផ្នួសជាភិក្ខុនោះ សម្ដេចព្រះឧទ័យរាជា ព្រះរាជបិតុលាសំរេចរាជការផែនដី យកព្រះនាងបុប្ផាវតីជាគូគុនាំង៉ានទ់នៃចៅពញា (តូ) ធ្វើជាព្រះជាយា ឲ្យហៅថា ព្រះម៉ែយ្យបុប្ផាវតី ។

ទៅពញា (តូ) ទ្រង់ព្រះផ្នួស ៥ វស្សា ព្រមអស់សេនាបតីមន្ត្រីគ្រប់ក្រសួងអញ្ជើញទៅពញា (តូ) ឲ្យដាក់ព្រះផ្នួសឡើងសោយរាជ-សម្បត្តិជាម្ចាស់ផែនដីក្រុងកម្ពុជាធិបតី ទ្រង់ព្រះនាមព្រះបាទសម្តេចព្រះស្រីធម្មរាជាព្រះរាជសំភារថ្លៃវិសេស សាងព្រះរាជវាំងគង់នៅគោះឃ្លោក កាលណោះព្រះជន្មបាន ២៥ ឆ្នាំ ។

សម្តេចព្រះឧទ័យរាជា ព្រះរាជបិតុលាដាក់ព្រះអង្គជាឧបយោរាជ្យគង់នៅ ព្រះរាជវាំងក្រុងឧត្តុង្គ ។

ក្រោយនោះសម្តេចព្រះឧទ័យរាជាព្រះរាជបិតុលា ទ្រង់មានព្រះឈួន ព្រះបាទសម្តេចព្រះស្រីធម្មរាជាព្រះរាជសំភារម្ចាស់ផែនដី ទ្រង់ស្តេចមកប្រថាប់ព្យាបាលព្រះរោគនៃសម្តេចព្រះឧទ័យរាជាព្រះរាជបិតុលា ខណៈនោះ សម្តេចព្រះឧទ័យរាជា ព្រះរាជបិតុលា ត្រាស់បង្គាប់ឲ្យព្រះរ៉ម៉ែយ្យបុប្ផាវតីរៀបគ្រឿងក្រយាស្ងោយ ថ្វាយព្រះបាទសម្តេចព្រះស្រីធម្មរាជាព្រះរាជសំភារសោយ ហើយសម្តេចព្រះឧទ័យរាជា ព្រះរាជបិតុលា ត្រាស់បង្គាប់ឲ្យព្រះរ៉ម៉ែយ្យបុប្ផាវតី ចេញមកគាល់ ព្រះបាទសម្តេចព្រះរាជសំភារជាម្ចាស់ផែនដី ។

ឯព្រះបាទសម្តេចព្រះស្រីធម្មរាជាព្រះរាជសំភារ ជាម្ចាស់ផែនដីក្រោយដែលទតព្រះនេត្រឃើញព្រះនាងបុប្ផាវតី ក៏មានព្រះរាជហឫទ័យគួចប្រតិព័ទ្ធដោយជាគូគ្នា ផ្ទាន់តាំងអំពីនៅជាព្រះរាជកុមារមកស្រាប់ ។

ក្រោយដែលព្រះរាជបិតុលាបានជាប្រឈួនហើយ ព្រះរាជសំភារជាម្ចាស់ផែនដី ក៏តែងមានព្រះរាជដំណើរមកគាល់សម្តេចព្រះបិតុលាជារឿយៗ សម្តេចព្រះទុទ័យរាជា ព្រះរាជបិតុលាបបួលក្រសាលបត្រង្គ មានសេចក្តីប្រៀបប្រាយជាពាក្យបំអកបំអន់ផ្សេងៗ មានពាក្យប្រៀប ១ បទជាពាក្យឃ្លោងថា "បាយឆ្នាជាផលស្លួយ ដំរីសារស្លាប់ជាក័ព្យកួយ ប្រពន្ធផង់ក្ពីយជាក័ព្យមា" ។

សម្តេចព្រះទុទ័យរាជា ព្រះរាជបិតុលាមិនស្គាល់ព្រះអង្គថា ជាទ្រង់ដល់នូវព្រះជរាភាព ។ បំណែកខាងព្រះបាទសម្តេចព្រះរាជសំភារម្ចាស់ផែនដី ព្រះជន្ម ៣០ ឆ្នាំ កំពុងពេញព្រះដំរេក តាំងព្រះរាជហឫទ័យបំណងយកព្រះនាងបុប្ផាវតីឲ្យខាងតែបាន ។

មានខណៈមួយ ម្ចាស់ផែនដី ស្តេចទ្រង់ព្រះរាជដំណើរដោយក្បួនព្យុហៈទៅធ្វើពិធីនមស្សការលើទីប្រាសាទនគរវត្ត ។ សម្តេចព្រះទុទ័យរាជា ព្រះរាជបិតុលានឹងព្រះម៉ែយួបុប្ផាវតី ក៏ស្តេចព្រះដំណើរព្រមនឹងម្ចាស់ផែនដីដែរ ខណៈដែលស្តេចឡើងទៅប្រាសាទនគរវត្តនោះ ម្ចាស់ផែនដីទ្រង់បានជួបចាប់ព្រះហត្ថានៃព្រះម៉ែយួបុប្ផាវតី កើតសេចក្តីប្រតិព័ទ្ធទៅវិញទៅមក ក្រោយស្តេចត្រឡប់មកពីនគរវត្តវិញ តាំងមានសុភអក្សរទៅវិញទៅមក ហើយទ្រង់ព្រះនិពន្ធជាពាក្យកាព្យរឿងនិរាសរឿងស្រណោះដូចមានសេចក្តីស្រង់ខ្លះៗ ខាងក្រោមនេះ:

ឃ្លាតខ្លួនឆ្ងាយស្ងួនប្រែទាំងចិត្ត បានត្រូកៀកជិតស្និទ្ធមូលមៃ
ផ្តេកផ្តិតនៃបនិត្យពល់យប់ថ្ងៃ ភ្លេចក្តីអាល័យរៀមអសារ ។
ចិត្តអើយសព្វថ្ងៃមិនភ្លេចគិត ដល់អស់ជីវិតទៅថ្ងៃណា
ទើបបានបែរបែកក្តីស្នេហា គនិផ្កាភ្លេចសោះអស់សង្ស័យ ។
ស្តាយចិត្តដែលបានប្តូរប្តេជ្ញា ស្តាយគ្រាកើតទុក្ខស្ទើរទឹងក្ស័យ
ស្តាយដែលធ្លាប់ជិតធ្លាប់អាល័យ ស្តាយមួយកាលថ្ងៃដែលប្រាសគ្នា ។
តាំងចិត្តគិតស្មានជាចាំពិត ដល់អស់ជីវិតដូចពាក្យថា
កាលដែលសន្មតប្តូរប្តេជ្ញា ទេវតាទ្រង់ជ្រាបទាំងអស់អើយ ។

ព្រះម៉ែយ្យបុប្ផាវតី បានទទួលព្រះរាជនិពន្ធច្បាប់នេះហើយ ក៏ថ្វាយបង្គំលាសម្តេចព្រះឧទ័យរាជា ចេញទៅក្រសាលបឹង សម្តេចព្រះឧទ័យក៏ទ្រង់អនុញ្ញាតឲ្យស្តេចទៅ គ្រាដែលព្រះម៉ែយ្យបុប្ផាវតីស្តេចចេញពីក្រុងឧត្តុង្គទៅដោយព្រះទីនាំងនាវា ស្តេចហួសមកជួបនឹងព្រះរាជសំការជាម្ចាស់ផែនដីនៅត្រើយពោធិ៍ព្រះបាទ នោះព្រះបាទសម្តេចព្រះស្រីធម្មរាជាព្រះរាជសំការជាម្ចាស់ផែនដី ទ្រង់នាំព្រះម៉ែយ្យបុប្ផាវតីទៅឯព្រះរាជវាំងកោះឃ្លោក ។

ខាងសម្តេចព្រះឧទ័យរាជា ព្រះបិតុលាបានជ្រាបហើយ ក៏ឲ្យលើកទាហានតាមទុយគេស់ទៅតាមចាប់ នោះព្រះរាជសំការម្ចាស់ផែនដីត្រាស់បង្គាប់ឲ្យលើកទាហានខ្មែរ ទាហានចិនចេញទទួលច្បាំង ខាង

ម្ចាស់ផែនដីខូចទាហានជាច្រើន ទ្រង់ត្រិះរិះយល់ថា សឹកខាងបច្ចាមិត្រ ខ្លាំងហួសកំឡាំង ទើបស្ដេចដោះព្រះអង្គចេញទៅ ដល់ទីមួយជាទីរហោះ ព្រៃមានដើមត្នោតជាច្រើន ក៏ស្ដេចឡើងលើដើមត្នោត ឯពួកពៃរីក៏លើក ទ័ពដេញព្រះអង្គបែកគេទៅ ។ ឯព្រះបាទសម្ដេចព្រះស្រីធម្មរាជាព្រះ រាជសំការម្ចាស់ផែនដី ទ្រង់ឈ្វេងដោយព្រះយោបល់យល់ថា មុខជាមិន រួចព្រះអង្គហើយ ក៏ទ្រង់ចាប់ព្រះទំរង់ត្រីមុខ កាត់ត្រួយត្នោតហើយ ចុះព្រះហស្ដលេខាចារព្រះរាជនិពន្ធពុំទាន់ចប់សេចក្ដី ខាងកងទ័ពបច្ចា- មិត្រក៏លើកទៅដល់នោះព្រះរាជសំការម្ចាស់ផែនដី ទ្រង់តាំងព្រះរាជ- ហឫទ័យដោយមានះក្សត្រ ទ្រង់បោយព្រះហស្ដ ហើយមានព្រះរាជ- តម្រាស់ទៅកាន់ពួកទាហានពរទុយគេស់ដោយព្រះសូរសៀងយ៉ាងខ្លាំង ថា: "បាពាំងអប្បល័ក្ខណ៍ រោបាមបាញ់អ្នក ព្រះរាជសំការ ពីលើចុង ត្នោត មិនកោតបេស្ដា អ្នកយកហត្ថា រាំងខាំងឃាត់" ។

សេចក្ដីខាងក្រោមនេះជាព្រះរាជនិពន្ធដែលទ្រង់ចារលើចុងត្នោត :

"សាធុសម្ដាយ កុំបីភយមាយ នឹងក្ដីកាមា
នាំឲ្យរង្វេង កង្វល់សង្សារ ស្លាប់ទៅកាលណា
បានសោយតែទុក្ខ ៗ ហេតុតែស្ដ្រី នាំឲ្យអប្រិយ
ដូចត្រីកង្កក់ បើបុរសផង បង់ខ្លួននរក
កុំភ្លេវក់ ដូចខ្ញុំបេះណា ៗ ពីព្រោះកាមេ

ឥឡូវទាល់តែ　ក្សិណក្ស័យដីក៏　សូវស្ងាប់ទៅគាប់
ឲ្យជាប់ធម្មា　សូមអស់ទេវា　ជួយជាទិព្វញាណ ។
ទើបព្រះភូមិន្ទ　នាកយន៍ធិបតិន្ទ្រ　ទ្រង់អធិដ្ឋាន
ពីនេះទៅមុខ　ខ្ញុំសូមឲ្យបាន　ជាព្រះពុទ្ធញាណ
នាំសត្វទាំងឡាយ ។　ឲ្យអ្នកទាំងពួង　ជាទាហានហួង
នាំយកទៅថ្វាយ　ព្រះបិតុលា　បានជ្រាបអធិប្បាយ
កុំឲ្យពាយមាយ　ទឹងក្ដីគាមេ" ។

លុះទ្រង់ព្រះរាជនិពន្ធរួចហើយ　ស្ដេចទំលាក់ចុះពីលើដើមត្នោត, តាហានពារទុគេស័ថ្វាយគ្រាប់មាសត្រូវព្រះអង្គធ្លាក់ពីលើដើមត្នោត, ខាងខ្មែរថា អស់ព្រះជន្មក្នុងខណៈដែលធ្លាក់ពីដើមត្នោត, ដំណើរខាងតាងប្រទេសថា នាំយកមកធ្វើទោសឯក្នុងក្រុង ។ ស្ដេចគង់ក្នុងរាជសម្បត្តិបាន ៥ ឆ្នាំ ទ្រង់ព្រះសុវណ្ណគតក្នុងព្រះជន្ម ៣០ ឆ្នាំ (គ. ស. ១៦៣០) ។

(ដកស្រង់ពីព្រះរាជប្រវត្តិ ដែលសម្ដេចក្សត្រីមាលិកាបានរួបរួមចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយាលេខ ១ — ឆ្នាំ ១៩៣៩ របស់ពុទ្ធសាសនបណ្ឌិត្យ)

---

## ច្បាប់ព្រះរាជសំភារ

ហៃសាធុជនផង　នេះគឺបំណង　បទបាលីថា　គម្ពីរសធម៌
អាណាក្រិតិកា　គួរគប្បីមហា-　ជនផងត្រងត្រាប់ ។　ធម៌នេះដំបូន្មាន
រួមរក្សាប្រាណ　ឲ្យបានក្ដីគាប់　ដល់លោកបរលោក　ហៅរស់ពុំស្លាប់
ធម៌នេះជាច្បាប់　ក្ដីគាប់បរិយាយ ៖

| | | |
|---|---|---|
| កុំទុកចិត្តបរទេស | កុំទុកចិត្តអតិទេស | កុំទុកចិត្តអតិប្រាយ |
| ប្រើសុំវែងខ្ពស់ | រំពឹងឲ្យឆ្ងាយ | ស្តាប់ពាក្យបរិយាយ |
| បណ្តាំមេដី ៗ | កុំងើងដោយខ្យល់ | កុំឆុនពាក្យពល |
| កុំខ្វល់ដោយស្រី | កុំកាន់ពិសយន៍ | គប់ទឹងស្រ្ដី |
| សមណជនជី | កុំឲ្យក្តីត្រូវ ៗ | កុំនៅញ៉ុំងឈ្មោះ |
| កុំស្តាប់អាសូពោះ | កុំស្តាប់អាស្រូវ | កុំដើរពានស្ទុន |
| កុំស្កាត់ប្រកផ្លូវ | កុំធ្វើស្រែស្រូវ | នៅផ្លូវដើរ ៗ |
| ផ្អែមពីរប្រការ | បំណោរនៅផាល | កុំអាលឲ្យធី |
| ផ្អែមមួយពាក្យពាល | តែងភលរកក្តី | ផ្អែមមួយពាក្យស្រី |
| ស្រួដមាយា ៗ | ពាក្យត្រូវវែងវង | ស្រាវែងស្រវឹង |
| ពុំដែលពីសា | ពាក្យពិតវែងស្វែង | ពុំពីពោះថា |
| បណ្តាំមេបា | វែងថាពុំគាប់ ៗ | ខ្សោវែងស្អប់ចេះ |
| ខ្សត់គតបំណោះ | ស្អប់អ្នកមានទ្រព្យ | ស្រីស្រាលប្រច័ណ្ឌ |
| វែងស្អប់ខ្ញុំគាប់ | ពាលពិតគតច្បាប់ | វែងស្អប់ប្រដៅ ៗ |
| ចង់បុណ្យបានបាប | ចងើងចង់លាក | វែងបាត់ធនទៅ |
| មានះបាត់មិត្រ | ឥតអ្នកជាំនៅ | គ្រេរគ្រោធយោរយោ |
| រមែងបាត់អត្ថ ៗ | ស្វែងគាប់បានយស | ចង់ស្វែងរបស់ |
| ប្រើចេះផ្តត់ផ្គង់ | ចង់ជំកុំអួត | ដើមមានពូជពង្ស |

ចង់ឲ្យខូចត្រង់ ប្រើផ្គប់អ្នកមុខ ៗ ខ្វែងហើរផ្សិតខ្យល់
ទាយច្រើនផ្សិតពល រក្សាឲ្យសុខ ទ្រព្យគង់ផ្សិតស្រី
បេះសំបៃទុក មានផ្ទះប្រណុក ផ្សិតករិយាជា ៗ
បាត់យសផ្សិតខ្ជិល បាត់ញាណទានសីល ផ្សិតសេពសុរា
ប្រមាទបាត់បុណ្យ ខឹងបាត់ប្រាជ្ញា លេញលេងដៀលថា
បាត់កិរិយាបថ ៗ អត់ឱនឥតទោស ធ្វើចិត្តសន្ដោស
បង្កើតជាទ្រព្យ មេត្រីជាញាតិ រក្សាដល់ស្លាប់
ចៀសក្ដីពុំគាប់ ជាគន្លពីដើរ ៗ ទឹកបាក់ទៅទាប
បុណ្យបាត់ផ្សិតបាប លាភបាត់ផ្សិតឃោរ ទឹកថ្លាផ្សិតរលក
ពុំយល់ស្រមោល ទោសកើតផ្សិតពោល ល្មមមាត់ឈ្លានពានៗ
ទៅវែងស្អប់ប្រាជ្ញ នាអ្នកខ្លួនខ្លាច វែងធ្វើជាហ៊ាន
ខ្សត់ខ្សោយស្ទុតទ្រុឌ វែងធ្វើជាមាន អ្នកឥតសន្ដាន
វែងមើលគេងាយ ៗ ទាហានច្រើនផ្សិតសឹក ធ្វើស្រែផ្សិតទឹក
ត្រេកពលផ្សិតបាយ សិស្សប្រាជ្ញផ្សិតគ្រូ ដេរពោលដំរាយ
ពលជាផ្សិតនាយ ហ៊ឹកហ៊ឺនខះខំ ៗ រៀនក្ដីគួរគិត
ចាស់ឥតប្រព្រឹត្ត ទូវែប្រែប្រឡំ អ្នកជាៗកាច
តូចប្រែជាធំ ពង្សពូជឧត្ដម ប្រឡំជាកស្ដ្រ ៗ
ឃើញសេះជាលា ក្ងានជាទា ពពាយជាទាស

សំណាជាប្រាក់ ស្អាទថ្លាក់ជាមាស បង្ក័យជាផាស
គប្បាសជាគ ៗ ហេតុនេះគួរគិត គួររិះរកហិត
ដីធ៌រសគន្ធ ពិដោរអេសុដោរ ពីសាសាទរ
ហិតហើយគប្បីប- រិភោគ្គាក្គិត ៗ ល្អិតព្រឹត្តពីពាក្យ
សាកសួររកសាប់ សន្ដានព្រេងព្រឹទ្ធ រករិះកលអ្វី
សុចរិតទុច្ចរិត ហើយហោងគួរគិត ឲ្យដឹងខ្ពស់ទាប ៗ
ដូចខ្វាក់ប៉ុំងស្បែក មួយដូចទំពែក ចង់សុំប្រេងលាប
ដូចចូង់ស្អាប់ប្រៀង ទះដៃព្រាក ៗ ដូចខ្វិនអាបឡាប
ចង់ចង់ក្បិនរត់ ៗ ពុតញួយមានបី មួយដូចដំរី
សាហាវឥតបទ អាចផ្សះផ្សាំងបាន កន្ធ្វើរកាន់កត់
ដាលដេញគោតគត់ ប្រាំមួយហត្ថហោង ៗ មួយចង់ឈ្នាទស
ចិត្តចង់ចចេស ពុំដោយគន្ធ៌ ពាក្យពោលអ្នកធំ
ប្រែទ្យំសួរសង់ ពុំគិតក្ដីហ្ន៍ ចង់ចេរអន្តរាយ ៗ
មួយស្រីពេស្យា បំពេញព្រហ្មចា- រីរួសអកប្រាយ
អំពើទាំងបី ហៅពិសពុតញាយ សាធុសម្ពាយ .
ចៀសកុំបីគ្រាប់ ៗ ល ៗ

## ការការពារខ្លួនដើម្បីទទួលសេចក្ដីសុខ

(តមក)

### ពោះវៀនធំជាពោះវៀនមនុស្សឃាត

**១.— ពោះវៀនធំជាសម្បុកជាតិពុល.—** ពោះវៀនធំមាន ៣ សង្កាត់ សង្កាត់ទី ១ គឺពីពោះវៀនតូចត្រង់កណ្ឌៀតក្អមខាងឆ្វេង ព័ទ្ធឡើងត្រង់មកលើ; សង្កាត់ទី ២ កាត់ពីចង្កេះខាងស្ដាំទៅចង្កេះខាងឆ្វេង កាត់ទទឹងពោះតាមចុងដង្ហើម; សង្កាត់ទី ៣ សំយុងចុះទៅកាន់ទ្វារលាមក ។

ពោះវៀនសំយុងចុះ ជាសម្បុកនៃមេរោគកប់គោជ, បើលាមកចេញស្រួលតាមប្រក្រតី មិនសូវឲ្យទោសប៉ុន្មានទេ តែបើលាមកនៅត្រាំក្នុងនោះយូរ មេរោគមានកំឡាំងបញ្ចេញពិសកាន់តែច្រើនឡើងៗ នាំឲ្យឈាមមានជាតិពុលលាយបន្តិចម្ដងៗ សន្សំៗ បង្កឲ្យកើតរោគាព្យាធិជាច្រើនប្រការ លុះលាមកដែលខ្ទក់ក្នុងពោះវៀនសំយុងចុះខាងឆ្វេងច្រាល់ដល់ពោះវៀនស្ដាំ នឹងនាំឲ្យកើតគ្រោះថ្នាក់យ៉ាងសម្បើម ដរាបដល់វះកាត់ទើបបានជាក៏មាន ។

**២.— ជាតិពុលក្នុងពោះវៀនធំជាសត្រូវយ៉ាងធំ.—** ជាតិពុលក្នុងពោះវៀននាំឲ្យខូចសរីរយន្ត នឹងសរីរកាយជាអនេកប្បការ ដូចមានពណ៌នាដោយសង្ខេបតទៅនេះ :

ក) ខូចសរសៃប្រសាទ.— ឲ្យអស់កំឡាំងពេកស្រពន់ជានិច្ច គឹងមុខគឹងមាត់ ឲ្យហួហៅ ឲ្យអផ្សុកធុញទ្រាន់ ដេកមិនលក់មមើមមាយៗ

ខ) ឈាមរត់មិនស្រួល.— កើតពេគស្បែក មានបូស កមមោស់ មុនជាដើម ត្រជាក់ដៃត្រជាក់ជើងប្រែះបបូរមាត់ ជ្រុះសក់ ខូចខួរក្បាលគិតការអ្វីមិនឮកៃ ៗ

ចំណែកខាងស្ត្រីបណ្ដាលឲ្យកើតបូសដោះ ពេលធ្លាក់ខែថ្ងៃ ល្ហិតល្ហៃអស់កម្លាំងដេកស្ដឹកជាច្រើនម៉ោងឬច្រើនថ្ងៃ ជួនក៏អាឥតកូន ជាហេតុនាំឲ្យស្វាមីព្រួយចិត្ត មកអំពីទោសលាមកក្ដៀននេះឯង ៗ

គ) ដង្ហើមខ្សោយ.— ពោះវៀនពុលនាំឲ្យខ្សោយដង្ហើម កាលបើដកដង្ហើមមិនបានល្អ ពោះវៀនក៏ខូចតាមគ្នា សម្បុរស្លាំង មុខក្រៀមមិនស្រស់ ទ្រូងគ្មានសាច់ ខ្នងកោង មាត់ចំហ កូនអាក្រក់ ៗ

## ៣.— ហេតុដែលនាំឲ្យលាមកក្ដៀន.— ដើម្បីការពារពេគ

ទល់លាមក គេងកំចាត់នូវហេតុដែលបង្កឲ្យកើតពេគនេះឡើង ហេតុទាំងនោះដូចម្ដេចខ្លះ?

ក) ទំលាប់ពោះវៀនមិនល្អ.— កូនក្មេងមិនពិនិត្យឲ្យវាបន្ទោបង់លាមករៀងរាល់ថ្ងៃ ដល់វាធំឡើង ពេលប្រញាប់ទៅរៀនក៏ប្រញាប់ប្រញាល់ស្រោះស្រួបដោយមិនទំពាឲ្យហ្មត់ហ្មង ឬក៏រវល់តែនឹងល្បែងទំទប់មិនទៅបន្ទោបង់ក៏មាន លុះធំឡើងជាប់ជំពាក់នឹងកិច្ចការច្រើន

ដំបូងមិនគិតដល់រឿងសំអាតពោះ ប្អូនក៏ស្មានខុសថា ក្នុងមួយថ្ងៃទៅបង្គន់មួយដងជាការគួរហើយ តាមពិតនោះត្រូវទៅពីរឬបីដងជានិច្ចទើបស្រួលខ្លួន ។

ខ) ទោសពីអាហារមិនល្អ — ខ្ជិលទំពាឲ្យគ្រប់គ្រាន់ អាហារគ្មានជាតិកំឡាំង (វីតាមីន) គ្មានទុកកាកដែលនាំឲ្យពោះវៀនកន្ត្រាក់ សរសៃបញ្ចេញចោលមកក្រៅ ជាហេតុឲ្យពោះវៀនខ្ជិលផង ។

គ) ទោសកើតពីមិនបំរើរាងកាយ.— ការមិនខំស្វាហាប់ធ្វើកាយកម្ម ប្រព្រឹត្តក៏ឡានាំឲ្យក្តៀនណាមក ដោយដុំសាច់និងសរសៃប្រសាទមិនសូវមានកំឡាំងខែងវែង ។

ឃ) កើតពីមេរោគ.— មេរោគដែលស្ថិតក្នុងពោះវៀនចូលទៅបានតាមច្រមុះនិងមាត់ ដោយមិនសំអាតខ្លួន ម្ហូបចំណី និងទីលំនៅឲ្យហ្មត់ហ្មង ។

**៤ — វិធីកំចាត់ជាតិពុលក្នុងពោះវៀន** — ដែលនឹងកំចាត់បាននោះ ដោយអាស្រ័យបំបាត់ហេតុដែលនាំឲ្យមានជាតិពុលនោះឯង មិនមែនដោយអារៈថ្នាំបញ្ចុះនោះទេ ។ ឯថ្នាំលាងៈពោះវៀនយ៉ាងវិសេសបំផុតនោះគឺ ប្រេងលោហធាតុ (huile parafine) ប្រេងនេះ ប្រព្រឹត្តរាល់ថ្ងៃបាន ព្រោះមិនជ្រាបចូលក្នុងពោះវៀន ហើយមិននាំឲ្យស្ដើងពោះវៀនផង ។ ឯវិធីកំចាត់ជាតិពុលនោះ ដូចតទៅនេះ :

ក) ទំលាប់ពោះវៀនឲ្យល្អ - ពេលត្រូវបន្ទោបង់ កុំបង្អែបង្អង់ ត្រូវទៅបន្ទន់ភ្លាម កុំបណ្តោយឲ្យទល់ហួសកំណត់មួយថ្ងៃឡើយ ។

ខ) ប្រិតរើសអាហារ - ទំពាឲ្យហ្មត់ហ្មង់ បរិភោគតែអាហារដែលឲ្យគុណ ។

គ) ធ្វើកាយកម្ម - គោងប្រព្រឹត្តកាយកម្មរាល់ៗព្រឹកនឹងកីឡារៀងរាល់អាទិត្យ គោងប្រឹងហាត់សរសៃពោះ ។

ដេកផ្ងារដាក់ដៃលើទ្រូង ហើយប្រឹងងើបអង្គុយឡើងដោយឥតកំរើកជើង ធ្វើឲ្យបានដប់ឬ ២០ ដងព្រឹកល្ងាច ។

ដេកផ្កាប់មុខ ងើយក្បាល ដាក់ដៃលើកញ្ចឹងក លើកជើងឡើងលើដោយឥតបន្ទន់ជង្គង់ ហើយរំលូនទៅមុខ ដោយផ្អៀងទៅឆ្វេងទៅស្តាំ ដូចកប៉ាល់ដែលត្រូវរលកពេលខ្យល់ព្យុះ បានចំនួន ៥ នាទី ព្រឹកល្ងាច ។

ឃ) កំចាត់មេរោគ - សំអាតខ្លួនឲ្យស្អាតជានិច្ច សំអាតមាត់ធ្មេញ ច្រមុះ កាត់ក្រចកកុំឲ្យដុះទាន់ អ្នកធ្វើអាហារគោងសំអាតដៃ សំអាតគ្រឿងផ្សំអាហារ ។

ផ្ទះសម្បែង គ្រឿងប្រើប្រាស់ ទីធ្លីភូមិគោងឲ្យស្អាតជាធម្មតា ។

ហាមក្មេងកុំឲ្យរាប់បរិភោគនំចំណីដែលដាក់លក់តាមមាត់ថ្នល់ នឹងការពារបំបាត់រុយដែលជាសត្វចង្រៃបំផុត កុំឲ្យមកទំលើម្ហូបចំណីអាហាររបស់យើង ។

# អនាម័យពេលព្រឹក

ពេលក្រោកពីដំណេក គេនឹកដល់អនាម័យជាដំបូង អនាម័យបង្គាប់ឲ្យយើងសំអាតរាងកាយដោយវិធី ៣ យ៉ាងជានិច្ចរៀងរាល់ថ្ងៃទាំងរដូវក្តៅ ទាំងរដូវត្រជាក់ ។

## ១.— សំអាតរាងកាយ — សំអាតដោយទឹក ដោយខ្យល់អាកាសនឹងសំអាតខាងក្នុង ។

ក) សំអាតដោយទឹក — មុជទឹកឲ្យជោកខ្លួន តាំងពីក្បាលរហូតដល់ចុងជើង បើខ្វះគ្រាន់តែស្រឡាបទឹកសព្វរាងកាយក៏បានដែរ តែមុននឹងស្រឡាបគេងដុសសាប៊ូលាងដៃឲ្យស្អាតជាមុន ព្រោះទឹកព្រឹកព្រហៀមកាលប៉ះនឹងរាងកាយរបស់យើង កន្ត្រាក់សរសៃឲ្យរត់ស្រួលព្រមទាំងសរសៃប្រសាទផ្សេងៗ មុជទឹករួច ជូតខ្លួននឹងដៃដុសឲ្យខ្លាំងរីតរួតទាល់តែស្ងួតទឹក សឹមយកកំណាត់ប្លុកនៃស្ងួតជូតដុសជាបង្ហើយកិច្ចចុងបំផុតប្រចាប់សព្វរាងកាយ ។

ខ) សំអាតដោយខ្យល់ — ពេលហាត់ប្រាណត្រូវនៅខ្លួនទទេឲ្យត្រូវក្រសែខ្យល់ បើហាត់ក្នុងបន្ទប់បើកបង្អួចឲ្យស្រឡះ ខ្យល់ព្រឹកព្រហៀមស្អាតល្អ នាំឲ្យឈាមរត់ស្រួល ហើយជួយឲ្យចំរើនកំឡាំងដកដង្ហើមផង ។

គ) សំអាតខាងក្នុង - ពេលក្រោកឡើងភ្លាម ត្រូវផឹកទឹកត្រជាក់មួយកែវយ៉ាងសន្សឹមក្រេបបន្តិចម្តងៗ រួចប្រះខ្លួនសំងំទៅវិញបានមួយស្របក់ សឹមហាត់កន្ត្រាក់សរសៃ ធ្វើបែបនេះ ជួយឲ្យស្អាតពោះល្អ ពោះវៀនខែងរែង លាមកក៏លែងកក្តៀនកក្តាំងសំងំនៅក្នុងពោះទៀតៗ

២.— គុណប្រយោជន៍នៃការនួតសរសៃ— ជាតិពុលមានច្រើនក្នុងសាច់ នាំឲ្យពុករួយស្រពន់ លុះមានគេមកនួតរឹតរួតឲ្យ អាការរួយស្រពន់នោះក៏បាត់ទៅ ដ្បិតការនួតសំរាប់កំចាត់ជាតិពុលក្នុងខ្លួនយើង ថែទ្រង់កំឡាំងធាតុ រក្សាកម្លាំងនឹងដុំសាច់ ជួយឲ្យដំរង់ទឹកសួតនឹងគ្រឿងយន្តសន្សំធាតុបុស្សសរសៃប្រសាទឲ្យដើរស្រួល នឹងជួយឲ្យឈាមរត់ល្អផងៗ

អាស្រ័យហេតុនោះ ជនខ្សោយគួរឲ្យគេនួតរឹតរួតឲ្យរាល់ៗព្រឹក ចំណែកជនដែលមានកម្លាំងខែងរែងហើយក៏គួរតែធ្វើដែរ តែកុំចាំបាច់ពឹងគេធ្វើឲ្យ រឹតរួតខ្លួនឯងជាកិច្ចគួរធ្វើណាស់ ដើម្បីធ្វើខ្លួនជាអ្នករហ័សរហែង ឯការនួតនោះ គឺចាប់កន្ត្រាក់សាច់គួសពាង្គកាយបានចំនួនប្រាំមីនុតជានិច្ចរៀងរាល់ពេលព្រឹកៗ

៣.— កាយកម្ម— អ្នកដែលប្រកបអាជីពដោយកម្លាំងបញ្ញានឹងខានប្រព្រឹត្តកាយកម្មមិនបានឡើយ ព្រោះរវល់តែអង្គុយគិត អង្គុយសរសេរ ចំណែកកាយឥតមានប្រើសោះ ដុំសាច់នឹងសរសៃប្រសាទក៏ទ្រុឌទ្រោមថមថយកម្លាំង ជាហេតុនាំឲ្យទល់លាមកកើតរោគាព្យាធិ

ច្រើន ដូចដែលយើងបានសង្កេតមកឃើញថា ជនចំពូកនេះច្រើនវិលមុខខ្យល់ចាប់ឬច្រើនកើតរោគរ៉ាំរ៉ៃដែលយើងរកាខ្លាចបំផុត ។

ចំណែកអ្នកប្រកបការចិញ្ចឹមជីវិតដោយកម្លាំងកាយវិញ កាយកម្មប្រព្រឹត្តរឿយៗ នឹងនាំឲ្យចំរើនសុខភាពគាន់តែសម្បូណ៌ល្អឡើង ព្រោះពេលដែលធ្វើការនោះមិនបានប្រើអវយវៈគ្រប់ព្រមទាំងអស់ទេ ប្រើអវយវៈណា អវយវៈនោះក៏ចំរើនទៅ ឯចំណែកអវយវៈឯទៀតបែរទ្រុឌទ្រោមទៅវិញក៏មាន ដូច្នេះអ្នកហាត់កម្លាំងត្រូវតែហាត់ប្រាណឲ្យបានចំរើនរាងកាយសព្វអន្លើស្មើៗភាគគ្នា ។

៤.— គុណប្រយោជន៍នៃការហាត់ប្រាណ— ការហាត់ប្រាណមានគុណប្រយោជន៍វិសេសណាស់ ត្រូវតែប្រព្រឹត្តរៀងរាល់ព្រឹក ចំនួនពី ៥ ដល់ ១០ នាទីបើមានពេលតិច ដោយយកចិត្តទុកដាក់ក៏ល្មមសមគួរហើយ ។

ក) ខាងអនាម័យ — នាំឲ្យឆ្ងាញ់បាយ ឲ្យស្រួលខ្លួន ឲ្យមានកម្លាំង ក៏ចាត់ជាតិពុលចេញពីក្នុងខ្លួន ខួរក្បាលបានសំរាកស្រួលល្អ ដោយឈាមថ្មីស្អាតរត់បរិបូណ៌ ឈាមកស្រួល ដង្ហើមចំរើនល្អ ។

ខ) ខាងលំអរាងកាយ — នាំឲ្យរាងកាយមាំមួនខែងរឹង មានទ្រង់ទ្រាយសក្តិសមល្អ ដំណើររហ័សរហួន ឫកពាអង់អាច ធ្វើការបានចំរើន សម្បុរក៏ស្រស់ ។

គ) ខាងសីលធម៌ — ឲ្យមានអំណត់ មានសេចក្ដីចំណានភងវៃ ស្មារតីពូកែ កម្លាំងចិត្តខែងរែង សេចក្ដីព្យាយាម សេចក្ដីក្លាហាន ជាដើម ។

៥.— របៀបដែលត្រូវប្រតិបត្តិតាម— ពេលក្រោកពីដេក ក្រេបទឹកមួយកែវយ៉ាងសន្សឹមៗ ប្រះខ្លួនសម្ងំមួយស្របក់ ហាត់កន្ត្រាក់សរសៃពោះ ចុះពីគ្រែ ឈរធ្វើកាយកម្មឲ្យត្រូវក្រសែខ្យល់ ទៅមុជទឹកជូតខ្លួនឲ្យស្ងួត ទុកខ្លួនប្រាណ អង្គុយសំរាកមួយស្របក់ សឹមស្រោះស្រង់រៀបចំខ្លួនចេញទៅធ្វើការ ។

បំពេញកិច្ចទាំងអស់នេះ ដោយសន្សឹមៗ យ៉ាងស្រួល កុំប្រញាប់ប្រញាល់ពេក តែកុំដំអក់ដំអែ ជាហេតុនាំឲ្យប្រអូសកាយប្រអូសចិត្ត ។

៦.— សេចក្ដីទុកចិត្ត— កាលបើយើងបំពេញកិច្ចអនាម័យតាមរបៀបខាងលើនេះ ដោយយកចិត្តទុកដាក់ទៀងពេលមិនដែលខាន ខួរក្បាលរបស់យើងក៏ថ្លាផូរផង់ល្អ មានកម្លាំងខែងរែង យើងតោងជឿជាក់ថា ខ្លួនយើងបានប្រតិបត្តិតាមច្បាប់អនាម័យសព្វគ្រប់ហើយ សុខភាពប្រាកដជាមានគង់ខ្លួនយើងជានិច្ច ឯខួរក្បាលរបស់យើងនឹងបង្គាប់បញ្ជាឲ្យសរីរយន្តរបស់យើងប្រព្រឹត្តទៅដោយស្រួលជាធម្មតា ។

# ការដេកលក់

ក្នុង ១ ថ្ងៃ ៗ យើងប្រើកម្លាំងជាច្រើន ទាំងកម្លាំងកាយ ទាំងកម្លាំងបញ្ញា ទាំងកម្លាំងចិត្ត កម្លាំងដែលចេញពីខ្លួនយើងទៅ យើងត្រូវបំពេញឲ្យមានដូចប្រក្រតីដើមវិញ បើមិនដូច្នោះទេ យើងនឹងរកកម្លាំងថ្មីប្រើពុំបានឡើយ ។ ការបរិភោគអាហារ គឺការបំរើនកម្លាំងរាងកាយ តែកម្លាំងខួរក្បាលពុំបានចំរើនដោយសារនោះផងទេ យើងដឹងហើយថាខួរជាអ្នកគិតគូរ ជាអ្នកបង្គាប់បញ្ជាសរីរយន្តទាំងមូល បើអ្នកបង្គាប់បញ្ជាខ្សោយហើយ ពួកពលក៏នឹងខ្សោយទៅតាម ប្រតិបត្តិការមិនបានរៀបរយទេ ព្រោះហេតុនោះ យើងគប្បីតែញុំាងកម្លាំងខួរឲ្យមានខែងរែងឡើង ឲ្យមានគុណភាពឡើង គឺការដេកលក់ ។

ការដេកមិនលក់ ដេកមិនឆ្អែតស្កប់ស្កល់បង្កើតទោសជាច្រើនប្រការ នាំឲ្យសាមីខ្លួនខ្វះថាមពលនឹងប្រឹងប្រែងធ្វើការ ឲ្យខ្ជិលច្រអូស ឲ្យស្រាយចិត្តគំនិត ឲ្យអស់សេចក្ដីក្លាហាន អស់ព្យាយាម ឲ្យធុញថប់ តប់ប្រមល់ មិនជ្រះថ្លា គិតការអ្វី ៗ ក៏មិនរហ័ស ជាមន្ទិលដល់ផលសំរេច ដល់ការកសាងខ្លួន ។

ចំណែកឯការដេកលក់ស្រួលពេញភ្នែក នាំឲ្យចំរើនសុខភាព ឲ្យថ្លាគំនិត ថ្លាភ្នែក សំឡេងស្រឡះ ឲ្យចំរើនកំឡាំងធ្វើការ ឲ្យរហ័សរហាន់ មានជីវិតស្រស់ស្រាយប្រៀបដូចដើមឈើ ដែលបានជ្រួយដីស្រោចទឹកជីល្អ

ហើយ មានពាក្យទំនៀមថា "អ្នកបានដេកលក់ដូចជាបានបរិភោគអាហាររួចហើយ" ។ មានអ្នកប្រាជ្ញខ្លះយល់ថា "វេលាដេកលក់ជាវេលាដែលជកឈប់ដើរ" អ្នកដេកលក់ស្រួល តាមដែលបានបង្កើតមក ឃើញថាក្រចាស់ ព្រោះហេតុនោះ ទើបក្មេងតូច ៗ ដេកច្រើនជាងក្មេងធំ ដល់ទៅចាស់ ដំណេកក៏រឹតតិចទៅទៀត ហាក់ដូចជាជកពេញពេលដេកលក់ឲ្យតិចចុះទៅតាមលំដាប់អាយុសង្ខារ ។

ហេតុដែលនាំឲ្យដេកមិនលក់នោះមាន ២ ប្រការ គឺ រាងកាយមិនសប្បាយ ១ គិតរវើរវាយពេក ១ ។ ខាងដើមយើងបានអធិប្បាយពីមុនមកហើយ អំពីត្រូវធ្វើដូចម្ដេចនឹងរក្សារាងកាយនេះឲ្យសម្បូណ៌ដោយសុខភាព ក្នុងទីនេះនឹងពោលតែពីការគិតរវើរវាយ ។ ដើម្បីកំចាត់ការគិតរវើរវាយនោះ យើងត្រូវហាត់ធ្វើការអ្វីគិតអ្វីធ្វើឬគិតឲ្យប្រាកដប្រជាដោយតាំងចិត្តឲ្យស្ងប់ក្នុងកិច្ចការនោះ កុំគិតបណ្ដើរឬធ្វើបណ្ដើរ ស្មុះទៅរកអារម្មណ៍ដទៃនាំឲ្យកើតកើនឲ្យស្រមាក់ស្រមៃ ធ្វើបែបនោះជាហេតុនាំឲ្យបានស្ងប់ដល់ពេលយប់ ។ តាំងចិត្តចូលដំណេកឲ្យទៀងពេលវេលា ដេកមុនម៉ោង ១២ យប់បានចំរើនជាងដេកក្រោយម៉ោង ១២ យប់ ហើយក្នុង ១ ថ្ងៃដេកលក់ឲ្យបានចំនួន ៨ ម៉ោងទើបប្រសើរ ។

វិធីនាំឲ្យដេកលក់ឆាប់នោះ ដូចតទៅនេះ សំរាករាងកាយឲ្យស្រួលកុំឲ្យមានប្រឹងត្រង់អវយវៈណាមួយ កុំកំរើក រួចដកដង្ហើមឲ្យវែងៗ

ស្មើៗ គ្នា ឈប់គិតអ្វីទាំងអស់ ។ បើដូច្នេះហើយនៅតែមិនលក់ព្រោះមានគំនិតណាមួយចេះតែចូលមកចៀតចៀនដោយមានះ សូមប្រើវិធីណាមួយបណ្ដាវិធីខាងក្រោមនេះ :

១– នឹកគិតដល់ក្ដារខៀនបញ្ឈរយ៉ាងធំយ៉ាងខ្ពស់មួយ ឲ្យឃើញតែខ្មៅគ្មានសណ្ឋានទ្រង់ទ្រាយ តែកុំប្រឹងពេក នឹកតាមធម្មតា ហើយកុំគិតដល់អ្វីឲ្យឃើញតែខ្មៅ ៗ ប៉ុណ្ណោះ ។

២– ផ្ទៀងស្ដាប់បេះដូង មួយស្របក់នឹងឮបេះដូងដើរ ហើយរាប់ការរីកក្ដោបនៃបេះដូងក្នុងចិត្តដោយយកចិត្តទុកដាក់ ។

៣– នឹកថាដេកក្នុងអង្រឹង ដែលយោលចុះឡើងមួយៗ នឹកដល់ការយោលឲ្យយ៉ាងស្រួល យ៉ាងនឹង យ៉ាងមានចង្វាក់ ។

៤– នឹកថាកំពុងរាប់លេខមួយៗ ហើយសរសេរដាក់ក្ដារខៀនតែពេលនឹកនោះកុំកំរើកខ្លួន ។

(មានត)

---

# កែតម្រូវ

ក្នុងសៀវភៅលេខ ៤-៥ ទំព័រ ១៩៩ បន្ទាត់ ១ ត្រង់ពាក្យថា "ធម្មបទថា..." កែជា "សំយុត្តនិកាយ សគាថវគ្គថា..." ដូច្នេះវិញ ។

៤

# ទុស្សន្តនិងសកុន្តលា

ទឹងថ្ងៃពីមទ័យវៃតាមស្តេច បានទាន់ស្រេចគេបច្រែករកទីនៅ
ក្នុងអាស្រមក្រំចិត្តគិតមួយហោង ខ្លាចព្រៃជ្រៅសុទ្ធខ្លាសត្វសាហាវៗ
បែរឯទឹកមិនស្អាតទីមិនស្រួល ណាមូសខាំកន្ទួលផ្លួលរសាវ
ណាស៊ីកឈើប្រែលើពុះប៉ើរប្រាវ ដូចគេការស៊ីកបេកដេកមិនបាន ៗ
សមអាហារក្រៀមក្រោះខ្សោះឥតជាតិ ព្រមទាំងឃ្លាតសុភការកំសាន្ត
មទ័យធាត់ភ្ញាត់ស្តមទ្រមអស់ប្រាណ ព្រួយរំខានទំផ្ចង់អង្វរថា ៗ
"ព្រះបក្រីប្រណីទូលបង្គំ ស្តេចចេញចាកអាស្រមវិលបើមា
ខំគង់នៅយូរទៅសៅកក្រ្តា ព្រះកាយាស្រពាប់ពុំគប្បី ៗ
ទូលបង្គំដម្ងឺឈឺពេលរុក ទ្រាំតែទុក្ខមុខជាដាច់ជីវី
សូមប្រញាប់នាប់ប្កានហានបុរី ព្រះបក្រីប្រណីទូលបង្គំ" ៗ
តែព្រះអង្គពុំស្តាប់សព្វសំដី "មិនទៅទេបុរីកុំរងំ
បើទឹងទៅត្រូវស្លាប់ដោយទុក្ខធំ ណ្ហើយកុំយំមទ័យសំឡាញ់ចិត្ត" ៗ
ពីបួបបួននួននាងសកុន្តលា ក្នុងគ្រមផាព្រះអង្គបង់ផ្តេកផ្តិត
ធ្វើម្តេចបានប្រាណស្រីមេត្រីស្និទ្ធ ទឹកមាសមិត្តភ្លេចគិតដល់នគរ ៗ
គង់តែក្នុងអាស្រមក្រំខ្លោចផ្សា ទឹកតៃកែវកនិដ្ឋាស្រស់បវរ

គន់សង្កេតនេត្រចាប់ហាក់អប្សរ    គួរត្រេកអរចរចូលទៅថ្នមថ្នាក់ ។
ថ្ងៃមួយមានបំរើព្រះមាតា    ឲ្យក្សត្រាវិលទៅរកសំណាក់
ជាប្រមុខបុណ្យធំឧត្តមសក្តិ    ទ្រង់ពុំស្ម័គ្រនឹងទៅនៅសំងំ ។
ទើបថៃវរកមហាត្ថិកបញ្ញាវៃ    “នែមច័យកុំស្ងៀមនៅក្រៀមក្រំ
ឆាប់ប្រមូលយោធាគិតរៀបចំ    ចាកអាស្រមទៅកាន់រាជធានី ។
សូមទោសាព្រះមាតាឲ្យខ្ញុំផង    កុំសៅហ្មងទៅចុះផុតសៀធី
ឲ្យបានសុខទុក្ខបាត់ខ្ចាត់គ្រប់ទី    មានជីវស្រស់ស្រាយកាយធំធាត់” ។
ពេលមច័យលៃដល់ទៅឋានថិត    ក្រេបចំណីវិចិត្រឥតឈប់មាត់
ទុស្សន្តរាជស្តេចស្តែងតែងខ្វាត់ក្វាត់    ត្រាច់រង្គាត់សួបសួងកូនព្រឹក្សា ។
សែនសញ្ជប់សញ្ជឹងរំពឹងកៃ    តែងគ្អូញត្អែតែងឯងថ្លែងផ្សា
រឹងទោម្នេញទ្រនេញខ្សឹបៗថា    “សកុន្តលា! សកុន្តលា! កល្យាណ៍បង” ។
ឧបដ្ឋាផ្កាស្រស់ល្អសកល    បងបានដល់ជួបប្អូនទឹងទន់ល្អង
ទន្ទនាងល្អសស្អាតគួរចាំចង    គួរចាំចិត្តថ្ងូរថ្ងើបងរក្សស្ងួន ។
ហាក់ត្រូវសរទម្លុះទ្រូងរូងក្តៅក្តាត់    ចាប់មិនបាត់ការតមករកនឹមនួន
គ្មានដំណឹងឈឹងស្ងាត់បាត់ទាំងខ្លួន    តើនាងព្រូនទីណា ធីតាអើយ ។
ស្បូបោលរាជសម្បត្តិខ្ចាត់ពីវាំង    ព្រោះកាន់គាំងស្មារតីឥតបើស្បើយ
ចិត្តស្នេហាប្រាថ្នានឹងកៀកកើយ    នឹងប្អូនហើយម្តេចឡើយគេចបោះដៃ ។

ក្លិនកេសរហោល ចាប់រសាប់រសល់
ស្មាននិមិលមកដាក់ស្រមាក់ស្រមៃ
ឱះឱ ក្លិនផ្កាសោះអាលោះអាល័យ
ពុំមែនថ្ងៃទុក្ខសល់រងឹខ្វល់រងឹខ្វាយ ៗ
យប់ឥន្ទុបន្ទ្រុត្រាប់បរពុំល្អពុំល្អះ
ចន្ទ្រស្រឡះជ្រះអស់ទើបស្រស់ទើបស្រាយ
គំនិតថ្លាឥតខ្ចោះរឹងក្បោះរឹងក្បាយ
បានសប្បាយក្នុងប្រាណសុខសាន្តសុខសម ៗ
ខ្យល់រំភើយល្ហើយដល់បន្អល់បន្អៀត
ទុក្ខសឹកស្បៀតស្ងាត់ស្ងៀមរែងក្រៀមរែងក្រំ
ពេលកលចិត្តឥតល្ហិះផ្សៃរិះផ្សំ
ឲ្យបានសមបំណងដែលផ្សងដែលផ្សំ ៗ
សកុន្តលា! សកុន្តលា! កល្យាណ៍កល្យាណ
ម្តេចមកច្រានប្រាណអូសរកូសរកាំ
តែមាំមួនខ្លួនបងឲ្យបងឲ្យចាំ
ឲ្យរងកម្មស្បើរប្រេះរលេះរលួយ ៗ
ឱ ពពកខ្មៅខ្ទាំងមកបាំងមកបិទ
ព័ទ្ធជុំជិតជាំជោករជោករង្គួយ

ព្រះចន្ទ្រាកប់បាត់ឱព្រាត់ឱព្រួយ!
ច័ន្ទ្រតែមួយត្រួយបិត្តមកបិទមកបាំង ។
មេឃងងឹតអ៊ូម្ល៉េះស្រងេះស្រងោច
វែងផ្កាខ្លាចរយពាន់ឲ្យភ័ន្តឲ្យភាំង
ឯពពកស្រុងស្មៅរឹតខ្មៅរឹតខ្លាំង
កម្អ៊ីខ្លាំងសណ្ឋានសោះសូន្យសោះសា ។
ពពកអើយអាណិតកុំបិទកុំបាំង
ឲ្យចន្ទ្រចាំងពេញមេឃភ្លឺផ្លេកភ្លឺថ្លា
ឲ្យខ្ញុំយង់យល់អង្គកក្រូត្រង់កក្រា
សកុន្តលា! សកុន្តលា! កល្យាណ៍កល្យាណ ។

បោះអាវុធចោលបង់យានត្រាក់ ព្រះបមបក្រកក្ដីសៅខ្មៅស្មោះស្មាន
ធ្លាប់គង់នៅទីស្អាតប្រាសាទឋាន ជាក្សេមក្សាន្តបានសុខឥតទុក្ខម្តង ។
មកឥឡូវត្រូវថ្ងៃក្តៅអស្ចារ្យ សមអាហារពុំបានប្រាណសៅហ្មង
តែឯកឯងត្រុកកុកព្រៃផង រកនួនល្អងទឹមនួនសកុន្តលា ។
ដំរះអង្គកង្ខុស៊ឹងរំពឹងគិត ដល់វរមិត្រឥតដាច់ពីចិន្តា
ពុំរសាយណាយពីក្ដីស្នេហា តឹងឧរាអួលណែនសែនចម្បង ។
មើលរលកស្រាញ់ញ៉ាញ់ទៅឆ្ងាយ ហូរផ្សព្វផ្សាយរង់ក្នុងគុម្ពត្រែង
អស់មច្ឆាលោតផ្លោតឥតកោតក្រែង ចឹកបុមខះខែងដណ្ដែងស៊ី ។

វល្លិ៍រំយោលដោលដល់ត្រួយស្លឹកឈើ បះទៅលើខ្យល់ច្រានរំខានវី
បុប្ផាផងម្លូហ្មង់ដោយកម្មរ៍ ព្រះភូមរ៍ងនឹកគិតគកល្យាណ ។
ចំណែកឯកល្យាណ៍ស្រស់ពុំងា ពីបានយល់ពជាមហាក្សត្រក្សាន្ត
ចិត្តរំភើបរញ្ជួយព្រួយរំខាន ឋិតក្នុងឋានពុំសុខបុកទុក ។
ពុំដឹងជាហេតុអ្វីទើបដូច្នោះ ញ័បញ័រពោះកាលបានឃើញក្សត្រា
លុះបាត់អង្គដោមចេតកើតទុក្ខា សោយសោកាអាល័យសង្ស័យខ្វល់ ។
ឆ្ងាប់ភ្នាកភ្នាយសាយសព្វអាស្រមឋាន ស្រាប់បែរបានខានសើចក្រៀម
ក្រំសល់
ធ្លាប់ប្រឹងប្រែងខ្វែងខំធ្វើកិច្ចកល បែរណាយចិត្តឥតរវល់ធ្វើតោះតើយ ។
ឯមាលីសួរក៏គួជីវិត ខំមកជិតល្អង់លោមក៏ពុំស្បើយ
ប្រើសប្រែលែងយ៉ាងណាគ្មានធូរឡើយ រៀងអ្វីអើយបានជាដូច្នេះអេះ ? ។
នាងបួលចិត្តទ្រមឹងឈឹងស្ងប់ស្ងាត់ យាត្រាកាត់ព្រឹក្សព្រៃដៃប្រលេះ
ស្លឹកឈើផងកងលេងទ័លចំណោះ តែឯកឯងស្រមេះពុំចេះថ្វា ។
បួនឈរលេងភ្លេចខ្លួនប្អូនប្រែប្រះ ទៅលើពូកដេរដាសដោយបុប្ផា
ហើយបាតដៃទាំងពីរបោលនេត្រា ទស្សនាអាកាសភ្លឺព្រោងព្រោយ ។
គន់មើលមេឃផ្ទេកខៀវខ្ចៀវស្រងាត់ ពពកសាត់សក្បុសតាមព្រះពាយ
ដូចស្បៃស្តើងឡើងស្រាលក្រាលរៀងកាយ ធ្លាក់ពីនាយដល់អាយឆ្ងាយ
ចេញបរ ។

ខ្យល់ត្រសៀករំភើយរឿយលើផ្កា   ផាត់កមកត្រឹបត្រង់ល្អង់កេសរ
សេឈ្មុយឈ្ងប់ត្រឡប់អប់ខ្លាយខ្លរ   លាន់អ៊ូអរដូចភ្លេងល្វេងសព្ទហាន ។
អាកាសព្រាតពន្លឺភ្លឺពណ្ណរាយ   នាំពយមាយសែនសល់ស្រស់ប្រាណ ។
ស្ទឹកបុិចពកពន្លកស្រស់ចំណាន   សូរប្ញានចែងចាំងរងើងរង្សី ។
សែនរំភើបស្រណោះនោះម៉ោះម៉ង   តែឯកអង្គផ្គង់គិតពីរឿងថ្មី
ឯធម្មជាតិជន្ទជន្ទេញស្រី   កល្យាណីឯកឯងចម្លែងខ្លាំង ។
គន់គន្ធឹងត្រង់ត្រឹបក្រេបកេសរ   បុប្ផាករអរស្រួលទទួលភាំង
បក្សីច្រៀងស្ទឹកខ្ទរស៊ូទាំង   ហើរហើយតាំងស្រែកច្រៀងកៀងគ្នា ។
គន់ៗ សព្ទថប់ថៃបែរសោយសោក   ហូរទឹកនេត្រសស្រោកទន់អង្គា
នាងទាញយកស្រទាប់បទុមា   មកធ្វើជាលិខិតចិត្តចរណៃ ។
“សារនៃចិត្តចិត្តអើយចិត្តក្រៀមក្រំ   ទុក្ខនេះចំចម្លែកចម្លែងក្រៃ
រីតរឹងតើតតើតចាប់តើតវិស័យ   មានអ្វីខ្វៃខ្វៃឈ្លោចខ្វៃរំខាន
ក្តៅស្មើរឆេះឆេះឆួល.ឆេះសន្ធៅ   ឆាបឆុំនៅនៅនិត្យនៅក្នុងប្រាណ
ខ្យល់បក់ហោកហោកផាត់ហោកប៉ុន្មាន   ពុំក្សេមក្សាន្តៗស្បើយក្សាន្តទុក្ខា ។
បុប្ផចមពង្សព្រៃស្រិតស្រោលចិត្ត   ឲ្យដាមជិតជិតដោយជិតដាលគ្នា
តាមព្រះអង្គអង្កែលអង្កែថា   បាត់បេស្តា ស្តារចិត្តស្តារពុំកើត ។
បាត់ក្តីមិន្ទមិនយល់មិនសប្បាយ   លោកប្រែក្លាយក្លាយជាតិក្លាយកំណើត ។
ស្ងាត់ឈឹងសូន្យសូន្យសោះសូន្យលែងកើត   ទឹងទឹកដើតដើតដើយដើត
ពុំរួច ។

លុះនាងចារសារសព្វប់សេចក្តី　　ទើបស្រស់ស្រីបង្ហើរដោយព្រឹព្រួច

ទៅតាមខ្យល់ឲ្យបក់ឆក់ទាញកួច　　ខ្ពស់ក្រលួចទៅកាន់ទុស្សន្តបង ៗ

តែស្រទាប់ផ្កាឈូកជូនហួសហេតុ　　ទឹងអណ្តែតពុំបានធ្លាក់ជាម្តង

នាងឃើញដូច្នោះកើតទុក្ខមួហ្មង　　ទើបនួនល្អងសោយសោកសោក

សង្រេង ៗ

លុះពត្រីខ្ទីអប់ដណ្តប់លោក　　ថ្ពាល់ដោរជោកទឹកនេត្រហៃងកន្ទួង

នាងរន្ធត់រវល់ខ្វល់វង្វេង　　ចាំគូព្រេងគេងកើយដៃសញ្ជប់ ៗ

ឯមាលីសួរក៏តាំងពីព្រាណ　　ចូលថ្នាក់ថ្នមកល្យាណលួងលោមសព្វ

យកស្លឹកឈូកបក់ផាត់មិនឲ្យថប់　　ហើយបន្ទប់បន្ទឹំបរៀងថា : ៗ

“ពេលព្រលប់យប់យូរស៊ូទ្រាំទៅ　　ណាពាលពៅនៅថ្ងៃស្រីកនិដ្ឋា

កុំសោកមាំនាំហ្មងសៅក្តៅ　　អន់ផាយាតោមងើតពុំកើតទេ ៗ

ដល់អរុណស្វាងផ្ទះព្រះសូរ្យា　　ព្រះក្សត្រានឹងមករកមាសមេ

តាមដូចបងផ្សងហើយពុំវៀចវេ　　ចូរតែរវេរះគិតចាំព្រះអង្គ ៗ

គេងឲ្យលក់ទើបបានរីកពយកក្ត្រ　　ប្រឹមប្រិយជាក់ជាល្អស្រស់បញ្ចង់

ស្តេចបានយល់មុខជាសំដៅត្រង់　　ប្រលោមអង្គណុងនួនសួនវរលក្ខណ៍ ៗ

ចូរគេងទៅពៅបងកុំហ្មងសៅ　　ស្វាមីចៅនឹងមករកនួនអ្នក

ម្ទិះក៏ផ្កាដូចបងបានផ្សងជាក់　　ពិតជាទាក់ស្វាមីមកឲ្យចៅ” ៗ

សកុន្តលាស្បើយទុក្ខមុខស្រស់ស្រាយ　　ទើបប្រះកាយលក់ល្វើយដើយ

អស់ក្តៅ

លុះព្រឹកព្រាងនាងភ្ញាក់ទឹងតាពៅ ស្ទុះទៅពៅស្អាងអង្គផ្ចង់ប៉ប្រិម ។
នាងចេញចាកអាស្រមទៅគុម្ពផ្កា ចាំកស្ដានាងនាថមាត់ញញឹម
ឥតសង្ស័យទោម្នេញពេញសង្ឃឹម ល្អឥតផ្ទឹមក្នុងទីដែនដីអាយ ។
ក្នុងគុម្ពផ្កាដែលបានយង់យល់គ្នា ក្នុងវេលាគ្រាមុនស៊ុនពីឆ្ងាយ
ឲ្យចាប់ចិត្តស្រណោះអាលោះស្ដាយ ឲ្យខ្វល់ខ្វាយទៅមកហៅរកគ្នា ។
ឲ្យស្រេងស្រៃងអាល័យនឹក ឲ្យសន្ទឹកសន្ធៃរងវេទនា
ឲ្យមមឹកមមៃលៃវេលា ស្រាប់ជោគជាជួបគ្នាជាបំផុត ។
ឯធម្មជាតិព្រោតព្រោងព្រឹសព្រួចព្រោយ កេសរពាយលំអងស្អាតបរិសុទ្ធ
ពិដោរឈ្ងុយល្ងួយល្ងើយក្រអូបមុត ដូចអាវុធចាក់ចុះថ្ងើមប្រមាត់ ។
ផ្ការីកថ្មីប្រិយប្រិមញញឹមស្រួល អរទទួលកមរវរប៉ាត់ញ៉ាត់
ឬកញ៉ែងញ៉ងញ៉ាំញ៉ើតាមខ្យល់ផាត់ តាមខ្យល់ផាយព្រាយព្រាត់សោ-
មនស្សា ។

ពួកបក្សីនៅសៀមត្រៀមចាំស្ដាប់ ស្ដេចសារសព្ទនឹងនាងសកុន្តលា
ដែលកៀកគិតស្និទ្ធស្នាលមូលចិន្ដា តើចរចាថាអ្វីតែពីរនាក់ ។
គួរស្ងួរស្ងឹងរង់ចាំចែកចាយសាយ ទឹកល្អឹកស្ងួរហ្ងួរឆ្ងាយផ្សាយពាក់ទាក់
ពាំនាំពាក្យប្រាប់ត្រង់ល្អងផាក់លាក់ ឥតគិតអាក់ស្ទើរគ្រប់ប្រាប់សព្វពាចា ។

(មានត)

## បញ្ញាត្រិះ (តមក)

សំឡាញ់ទាំងពីរនាក់នេះ ទៅមើលពិធីលេងមហោស្រពនោះ ទៅដល់ ដើរលេងពាក់ពួនមួយអន្លើដោយពួករបាំ ពួកតុក្កតា ពួកកំប្លែងនិងពួកជនដែលមកពីបរទេស កាលកំពុងតែដើរចុះដើរឡើងដូច្នេះ ក៏ក្រ-ឡេកទៅឃើញនាងខត្តិយកញ្ញាមួយអង្គល្អបំណាច់ ដ៏ប្រដាប់តុបតែងអង្គដោយគ្រឿងអាភរណៈសព្វគ្រប់ប្រការ ៗ ព្រះនាងគង់នៅលើដំរីមានស្ត្រីក្រមការនិងតម្រួតពាក់គ្រឿងក្រោះហែហមចោមរោមជាបរិវារ ស្តេចមកមើលបុណ្យនោះដែរ ៗ ឯអ្នកតម្បាញ កាលដែលមើលទៅឃើញនាងខត្តិយកញ្ញានោះភ្លាម ត្រូវសរកាមទេពបាញ់មកមុតដល់ថ្លើមដួលត្បូងដល់ដីសន្លប់មួយរំពេចហាក់ដូចជាគេត្រូវថ្នាំបំពុល ឬ ហាក់ដូចជាខ្មោចគាប់ដូច្នោះ ៗ ជាងរថ លុះក្រឡេកឃើញសំឡាញ់ខ្លួនដួលដូច្នោះក៏ស្រឡាំងកាំង កើតទុក្ខព្រួយចិត្តទើបពឹងគេឯងដែលមានកម្លាំងឲ្យជួយគ្រាហ៍លើកនាំយកទៅផ្ទះខ្លួន ៗ ដោយការប្រោះព្រំធ្វើឲ្យត្រជាក់ ដោយការធ្វើតាមបង្គាប់គ្រូពេទ្យដោយប្រការផ្សេងៗ និងដោយការស្តោះព្រួសនៃគ្រូមន្តអាគម អ្នកតម្បាញនោះមិនយូរប៉ុន្មានក៏បានដឹងខ្លួនមានស្មារតីឡើងវិញដោយការឈឺឆ្អាលមើលនេះ ៗ កាលនោះ ជាងរថសួរទៅកាន់អ្នកតម្បាញដោយឆ្ងល់ថា: “នែមិត្ត! ហេតុអ្វីក៏ឯងស្រាប់តែសន្លប់សន្លិនបាត់ស្មារតីមិនដឹងខ្លួនដូច្នេះ? ចូរឯងនិយាយប្រាប់តាមដែលឯងដឹងមក

មើល !" ។ អ្នកតម្បាញឆ្លើយប្រាប់ថា: "បើដូច្នោះ ចូរឯងចាំស្តាប់ ! ខ្ញុំនិយាយប្រាប់រឿងសំងាត់តាមដែលខ្លួនខ្ញុំដឹងទាំងអស់ តែបើឯងទុកខ្ញុំជាសំឡាញ់ពិតមែន ចូរឯងមេត្តារៀបចំរកឧសភ្លើងរៀបជើងថ្ករទុកឲ្យគ្នាស្រេចទៅ, មួយទៀត ចូរសំឡាញ់មេត្តា ថាបើខ្ញុំមានទោសធ្ងន់ធ្ងរចំពោះសំឡាញ់ឯងយ៉ាងណាខ្លះ សូមអភ័យទោសកុំខាន ។ ជាងរថបានស្តាប់ពាក្យអ្នកតម្បាញចប់ហើយ រឹតតែរន្ធត់តក់ស្លុតថែមទៀត និយាយទាំងប៉ប៉េបប៉ុប ទឹកភ្នែកស្រក់ស្រោកយំបណ្តើរនិយាយបណ្តើរថា ទេ ! ទេ ! ទោះជាឯងមានទុក្ខធ្ងន់យ៉ាងណាក៏ដោយ ត្រូវតែឯងប្រាប់យើងឲ្យឆាប់ៗមក យើងនឹងគិតរកថ្នាំមកថែរក្សាឲ្យបានជាសះស្បើយឆាប់ទៅ ថាបើជម្ងឺគាប់មើលបាន, ព្រោះថា :-

២០៣- នៅក្នុងលោកដែលឋិតនៅកណ្តាលព្រហ្មាណ្ឌ:(១) នេះ មិនមានអ្វីមួយដែលគេមិនត្រូវបំពេញបំណងដោយថ្នាំ ដោយពាក្យដំបូន្មាន ដោយប្រាជ្ញា នឹងដោយធនមានមហាគុណទាំងឡាយទេ" ។

ថាបើបំណងទាំង ៤ ប្រការនេះ គេត្រូវបំពេញឲ្យកើតមាន ខ្ញុំនឹងបំពេញបំណងនោះឲ្យសម្រេចក្នុងកាលឥឡូវនេះ ។ អ្នកតម្បាញឆ្លើយតបថា: 'សំឡាញ់អើយ ! បើទុកជាយើងទាំងពីរនាក់នេះ មានឧបាយឆ្លៀវឆ្លាតដល់ទៅមួយពាន់ន័យ ក៏មិនអាចនឹងរម្ងាប់សេចក្តីទុក្ខខ្ញុំបានទេ

---

១ ស៊ុតនៃព្រហ្មគីលោកនេះ ។,

ព្រោះហេតុនោះ ចូរសំឡាញ់កុំបង្អាក់សេចក្ដីស្លាប់របស់ខ្ញុំ នាំពន្យឺតឲ្យយឺតយូរកាលវេលាឥតប្រយោជន៍ ។ ជាងរថទូបនិយាយទៅទៀតថា: "ឱមិត្រសំឡាញ់អើយ! ជាបើទុកជាជួយដោះទុក្ខធុរៈឯងមិនបានទេ ក៏ត្រូវតែឯងនិយាយប្រាប់យើងឲ្យបានដឹងដែរ បើខ្ញុំយល់ថារកថ្នាំជួយមើលឯងមិនបានមែន ខ្លួនខ្ញុំក៏ត្រូវតែលោតចូលទៅក្នុងភ្លើងជាមួយឯងដែរ ព្រោះខ្ញុំមិនអាចទប់ទល់សេចក្ដីទុក្ខ ដែលកើតពីការព្រាត់ប្រាសឯងនេះបានទេ កុំថាឡើយដល់ទៅយូរ សូម្បីតែមួយខណៈក៏មិនបានផង នេះជាសេចក្ដីសម្រេចនៃចិត្តរបស់ខ្ញុំ" ។ ទីបំផុត អ្នកតម្បាញអត់ទ្រាំមិនបានក៏ឆ្លើយប្រាប់ថា: "សំឡាញ់អើយ! កាលដែលខ្ញុំក្រឡេកមើលទៅឃើញខត្តិយកញ្ញានៅលើដំរីក្នុងពិធីបុណ្យនោះ កាមទេព(១) ដែលមាន

---

១ តាមរឿងព្រេងថា អសុរឈ្មោះសម្ពរៈបានបោះកាមទេពទៅក្នុងសមុទ្រ ហើយត្រីលេបបាត់ទៅ ។ ត្រីនោះត្រូវព្រានប្រម៉ង់ចាប់បានហើយយកទៅឲ្យសម្ពរៈ ។ សម្ពរៈនេះយកភរិយាកាមទេពដែលមានឈ្មោះថានាងមាយាវតីទៅទុកជាខ្ញុំបំរើ ។ ដល់គេវះត្រីនោះទៅគេឃើញមានកូនមួយ នាងមាយាវតីយកកូននោះទុកជាកូនខ្លួន ហើយទុកខ្លួនជាម្ដាយនៃកូននោះ ។ តមក, កាមទេពនោះស្គាល់ថានាងមាយាវតីនេះជាភរិយាខ្លួន ដែលឈ្មោះថារតី ព្រោះហេតុនោះ បានជាកាមទេព មានមករជាទង់ជ័យ ។

មករដោទន់ដ័យបាញ់សរមកត្រូវចំដួងចិត្តខ្ញុំ ខ្ញុំទប់ទល់ចំពោះកាមទេពនោះមិនបានសោះទាល់តែដល់សន្ធប់យ៉ាងនេះ(១)" ។

លុះបានស្តាប់ដំណឹងសេចក្តីថារឿងនេះកើតមកពីក្តីស្នេហា ជាងរថញ-ញឹមហើយនិយាយនាំឲ្យក្លាហានថា: "សព្វបើរឿងប៉ុណ្ណឹងមិនហ៊ានប្រាប់គ្នា យើងនឹងធ្វើឲ្យសម្រេចតាមបំណងយើងឥឡូវនេះមិនខាន យើងនឹងទៅជួបនឹងខត្តិយកញ្ញានោះថ្ងៃនេះឯង ។ អ្នកតម្បាញទឹកឆ្ងល់សួរទៅថា "នៅក្នុងរាជសំណាក់ព្រះនាង វៀរលែងតែព្រះពាយ ឥតមាននរណាមួយក្លាហានអាចចូលទៅដល់បានទេ ព្រោះមានតម្រួតត្រួតយាមល្បាតសព្វកាលវេលា ធ្វើដូចម្តេចយើងនឹងអាចចូលទៅឲ្យដល់បាន? បើដូច្នេះគោតតែឯងមកនិយាយកុហកគ្នាលេងទទេកើតហ៎?" ។ លុះនិយាយគ្នារួចហើយ

---

១ បញ្ចតន្ត្រ: សេចក្តីប្រែជាភាសាបារាំងនៃលោកឡុងសឺរ មានគាថាលើសដូច្នេះ ក— អាត្មាអញនឹងបានដេកក្នុងទ្រូង គឺការឱបនៃនាង នឹងបានក្រេបរសជាតិសម្ផស្ស ការប្រកៀកប្រឱបនឹងឡើយ ដោយការអស់កម្លាំងសន្ធវកិច្ចហើយដេកលើទ្រូងប្រដាប់ដោយសុដន់ទាំងគូមូលក្លំ ដូចពោងក្បាលដំរីចុះប្រេងដំសើមដោយម្សៅរមៀត ដល់កាលណាហ្ន៎! ខ— ពពីមាត់ក្រហមដូចផ្លែពិម្ពា សុដន់ទាំងពីរមូលក្លំក្បំលេចឡើងដោយការនៅវ័យក្មេង ផ្ចិតខ្វូងជ្រៅ ផ្កាឈូកគឺគុយ្ហប្រទេស រាងរៅរៀវស្ដេញស្ដើ នៅក្នុងលោកនេះ អវយវៈទាំងឡាយនេះ កាលណាបើគេនឹកឃើញហើយ នឹងនាំឲ្យចិត្តរសាប់រសល់ខ្វល់ខ្វាំងណាស់ ថ្ពាល់នាងទាំងគូភ្លឺផ្លេកនេះ ផុតកំដៅចិត្ត ឲ្យក្តៅសព្វមិនឲ្យធូរស្រាលសោះ រឿងអស់នេះ មិនគួរនាំឲ្យអាត្មាអញយ៉ាងនេះសោះ! ។

ផាន់វេថចាប់កសាងរូបគ្រុឌ[1] ភ្លាម ធ្វើពីឈើអង្គុនព្រឹក្សដែលកើតយូរហើយ គាត់ធ្វើឲ្យមានដៃ ៤ មានស័ង្ខ មានកង់ចក្រ មានដំបង មានផ្កាឈូក មានមកុដ មានសង្វារកៅស្ទុភ:[2] សុទ្ធសឹងជាគ្រឿងឧបករណ៍ព្រះនារាយណ៍ ព្រមទាំងមានគន្លឹះយន្តទាញចុះឡើងឲ្យហោះហើរបាន ។ សាងរូបគ្រុឌរួចហើយ ផាន់វេថឲ្យអ្នកតម្បាញឡើងជិះលើគ្រុឌយន្តនោះ ឲ្យតែងខ្លួនដូចជាព្រះវិស្ណុ បង្រៀនឲ្យបេះកាន់យន្តស្ទាត់ហើយបង្គាប់ថា: "សំឡាញ់! សំឡាញ់តែងខ្លួនជាព្រះវិស្ណុហើយហោះទៅសំណាក់នាងខត្តិយកញ្ញានោះចុះ ក្នុងពេលយប់ព្រះនាងប្រថាប់នៅតែមួយព្រះអង្គ ឯងនៅក្នុងប្រាសាទខាងលើជាន់ទីប្រាំពីរ កាលព្រះនាងទតឃើញឯងនឹងគិតយល់ថា ព្រះវាសុទេព[3] ឯងថែចង់ដោយសំដីបោកបញ្ឆោត ហើយនឹងបានត្រេកអរសប្បាយជាមួយនឹងព្រះនាងដោយវិធីវាត្ស្យាយន:[4] ពុំខានឡើយ" ។ ឯអ្នកតម្បាញ ទទួលស្ដាប់ពាក្យផាន់វេថហើយក៏តែងខ្លួនជាព្រះវាសុទេព ហោះទៅក្នុងពេលរាត្រីស្ងាត់ ចូលទៅដល់សំណាក់ព្រះនាងហើយសួរថា: "ហៃព្រះនាងរាជបុត្រី! ព្រះនាងផ្ទំលក់ហើយឬនៅឡើយទេ ព្រោះតែជាប់ចិត្តរូបសោភាព្រះនាង បានជាយើងចេញចាកសមុទ្រ[5] លះបង់ចោលព្រះនាងលក្ស្មី[6]

---

១ គ្រុឌជាស្ដេចបក្សី ជាជំនិះព្រះវិស្ណុ ជាកូននាងវិនតាដែលជាភរិយានៃព្រះកស្សបៈ ។ ២ សង្វារនេះ កើតពីការកូរសមុទ្រទឹកដោះ សម្រាប់ប្រដាប់ព្រះវិស្ណុឬព្រះក្រឹស្ណ ។ ៣ នាមព្រះវិស្ណុ ។ ៤ វាត្ស្យាយនៈ អ្នកប្រាជ្ញឥណ្ឌាតែងគម្ពីរកាមសូត្រយ៉ាងចំណាន ។ ៥ សមុទ្រជាលំនៅនៃព្រះវិស្ណុ ។ ៦ នាងនេះកើតពីការកូរសមុទ្រទឹកដោះ បានជាភរិយាព្រះវិស្ណុ ។

មករកនាងដោយក្ដីស្នេហាដ៏ក្រៃលែង ចូរមកយើងទឹងសមាគមត្រេកត្រអាលជាមួយគ្នាឥឡូវនេះ" ។ ព្រះនាងខត្តិយកញ្ញា លុះក្រឡេកទៅឃើញអ្នកតម្បាញក្លែងខ្លួនជាព្រះវិស្ណុជិះគ្រុឌ មានដៃ ៤ មានគ្រឿងឧបករណ៍ជាអាវុធ ព្រមទាំងសង្វាកៅស្តុភ: ភ្ញាក់ខ្លួនព្រើត ស្ទុះចាកទៃនសយនាក្រឡាបន្ទំដោយក្ដីឆ្ងល់ លើកទសករប្រណម្យដោយគោរពហើយត្រាស់សួរថា: "ភគវ័ន! ខ្ញុំព្រះអង្គជាស្ត្រីមនុស្ស ជាសត្វមិនស្អាតទ្រង់ព្រះករុណាជាភគវ័ន ជារតនវត្ថុគួរគោរព ជាអ្នកបង្កើតត្រៃលោកនេះផង ធ្វើដូច្នេះ មិនគួរដល់ព្រះអង្គទេ" ។ អ្នកតម្បាញឆ្លើយតបវិញថា: "ហៃប្អូនសំឡាញ់អើយ! ប្អូននិយាយនេះពិតជាត្រូវហើយ ប៉ុន្តែរឿងនេះធ្លាប់មានមកហើយក្នុងកាលពីដើមគឺព្រះនាងពធ:(១) ដែលកើតក្នុងត្រកូលនន្ទ: ធ្លាប់បានមកជាភរិយាបងដែរ នាងពធ:នេះអាវគារមកជាប្អូន ព្រោះហេតុនេះហើយបានជាបងមករកប្អូន នាងខត្តិយកញ្ញានិយាយតទៅទៀតថា: "ភគវ័ន! បើដូច្នោះ សូមទ្រង់មេត្តាប្រោសអញ្ជើញទៅសូមដល់ព្រះវរមាតាបិតាខ្ញុំព្រះអង្គសិន ដើម្បីឲ្យទ្រង់ប្រោបហើយថ្វាយដល់ទ្រង់ព្រះករុណាសោះសង្ស័យ" ។ អ្នកតម្បាញឆ្លើយតបថា: "ឱប្អូនអើយ! គ្រាន់តែក្លែងខ្លួនជាមនុស្សមិនបានទៅហើយ ចាំបាច់និយាយថ្វីដល់ទៅនិយាយទៀត សូមប្អូនស្រីប្រគល់ខ្លួនឲ្យមកបង ព្រមធ្វើ

---

១ នាងនេះជាភរិយាជំនិតនៃព្រះក្រឹស្ណៈក្នុងគ្រាកាលដែលក្រឹស្ណៈឃ្វាលគោនៅប្រទេសវ្រជៈ ក្បែរត្រើយស្ទឹងយមុនា ។

តាមគន្ថាវិភាគៈ ក្នុងកាលសព្វថ្ងៃនេះ បើមិនដូច្នោះទេ បងនឹងបំផ្លេចបំផ្លាញ
ឲ្យល្អិតទៅជាផេះផង់ធូលីក្នុងកាលនេះឯង និយាយយ៉ាងនេះហើយ ក៏ចុះ
ចាកគ្រែឱហើយចូលទៅ យកដៃឆ្វេងចាប់ព្រះនាងខត្តិយកញ្ញា ដែលកំពុង
ភិតភ័យតក្កមា ស្រៀវខ្លាច ញាប់ញ័ររន្ធត់ ឱបក្រសោបយកទៅកាន់
ទីទនសយនា ហើយកើតក្រេកក្រេតអាលជាកាមវិស័យហេតុទាល់ក្ដីតាម
វិធីដែលអ្នកប្រាជ្ញរៀបសព្វាយនៈបានចារិកទុក ដល់ព្រឹកព្រាងឡើង ក៏
យាត្រាទៅកាន់ផ្ទះខ្លួនវិញ ឥតឲ្យអ្នកណាមួយដឹងយល់បានឡើយ ។ អ្នក
តម្បាញតែងទៅកាន់សំណាក់ព្រះនាង ហើយក្រេកក្រេតអាលដោយ
កាមពតជានិច្ចកាលតទៅ ។ តមកថ្ងៃមួយ ពួកបរិវារជាអ្នកថែរក្សាមើល
ឃើញរមែតពីព្រះឱស្ឋនៃព្រះនាងប្រែ ហើយនិយាយខ្សឹបខ្សៀវគ្នា
ដោយភិតភ័យរបស់ថា: "ឱងាប់ហើយ ឯងមើលហ្ន៎ ! ព្រះសរីរាវយវៈ
នៃព្រះនាង មើលទៅឃើញហាក់ដូចជាមានប្រុសឈ្មោលចូលទៅប៉ះ
ពាល់ហើយ ប្រាសាទពជនិវេសន៍នេះ យើងបានថែរក្សាប្រយ័ត្នម៉ឺងម៉ាត់
ណាស់ ហេតុដូចម្ដេចក៏មានអ្នកណាហៅហានអាចហ៊ានចូលមកប្រព្រឹត្ត
យ៉ាងនេះបានហ្ន៎ ? រឿងនេះ យើងនៅស្ងៀមព្រងើយកន្តើយមិនបានទេ
ត្រូវតែទូលទៅគាល់ព្រះករុណាជាម្ចាស់ ហើយយកសេចក្ដីនេះក្រាបបង្គំ
ទូលឲ្យទ្រង់បានជ្រាបដោយសព្វគ្រប់" ។